# ខចែង និងលក្ខខណ្ឌ

## ខចែង និងលក្ខខណ្ឌសម្រាប់សេវាធនាគារអ៊ីនធើណែត និង/ឬសេវាធនាគារចល័ត RHB Now

ខចែង និងលក្ខខណ្ឌនេះ គ្រប់គ្រងការប្រើប្រាស់សេវាធនាគារអ៊ីនធើណែត និង/ឬ សេវាកម្មធនាគារចល័ត (ដែលតទៅនេះត្រូវបានហៅកាត់ថា "**សេវាកម្ម**") និងអនុវត្តចំពោះអតិថិជនដែលមានសិទ្ធិប្រើប្រាស់ ក្នុងគោលបំណងជួយសម្រួលដល់អតិថិជនទាំងនេះឲ្យអាចចូលទៅប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិច នូវគណនីរបស់ខ្លួន ផលិតផល និងសេវាកម្មដទៃទៀតរបស់ធនាគារដូចដែលបានផ្តល់ជូនដោយធនាគារ RHB Indochina Bank Limited (ដែលតទៅនេះត្រូវបានហៅកាត់ថា "ធនាគារ RHB") តាមរយៈគេហទំព័រ www.rhbnow.rhbgroup.com/kh (ដែលតទៅនេះត្រូវបានហៅកាត់ថា "**គេហទំព័រ**")។

តាមរយៈការចុះឈ្មោះដោយជោគជ័យជាអ្នកប្រើប្រាស់សេវាធនាគារតាមអ៊ីនធើណែត ឬសេវាធនាគារចល័តរបស់ធនាគារ RHB និងតាមរយៈការចូលទៅប្រើប្រាស់សេវាកម្មទាំងនេះ លោកអ្នកទទួលស្គាល់ និងព្រមព្រៀងថាខចែង និងលក្ខខណ្ឌនេះចងកាតព្វកិច្ចចំពោះលោកអ្នក និងត្រូវបានចាត់ទុកថាជាកិច្ចព្រមព្រៀងរវាងលោកអ្នកដែលជាអតិថិជន និងធនាគារ RHB (ដូចដែលបានបញ្ជាក់ក្នុងប្រការ១.១៧ ខាងក្រោម) ចំពោះការចូលទៅប្រើប្រាស់ និង/ឬការប្រើប្រាស់សេវាកម្មទាំងនេះ។

ខចែង និងលក្ខខណ្ឌនេះពេលបច្ចុប្បន្នជំនួសឲ្យខចែង និងលក្ខខណ្ឌពីមុនទាំងអស់ដែលលោកអ្នកបានទទួល ឬបានប្រើប្រាស់តាំងពីមុនរហូតដល់ពេលបច្ចុប្បន្នតាមរយៈគេហទំព័រ និង/ឬ ឧបករណ៍អេឡិចត្រូនិចចល័ត។ ការបន្តការប្រើប្រាស់ និង/ឬ ការបន្តចូលទៅប្រើប្រាស់នូវសេវាកម្មទាំងនេះរបស់លោកអ្នក នឹងត្រូវបានចាត់ទុកថាជាការទទួលយកនូវខចែង និងលក្ខខណ្ឌនេះ។

កិច្ចព្រមព្រៀងនេះត្រូវបានអានក្នុងពេលតែមួយជាមួយនឹងខចែង និងលក្ខខណ្ឌនៃផលិតផល និងសេវាកម្មនីមួយៗ និងជាក់លាក់ដទៃទៀត ដែលធនាគារ RHB អាចចែង/បង្កើតតាមពេលវេលាជាក់ស្តែង។ តាមការយោងនៅក្នុងប្រការនេះ ខចែង និងលក្ខខណ្ឌនៃផលិតផល និងសេវាកម្មនីមួយៗ និងជាក់លាក់ត្រូវបានចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ។

## ១. និយមន័យ

នៅក្នុងខចែង និងលក្ខខណ្ឌនេះ ប្រសិនបើបរិបទមិនតម្រូវផ្សេងពីនេះនោះទេ វាក្យស័ព្ទខាងក្រោមមានអត្ថន័យដូចខាងក្រោម៖

១.១ "លេខសម្គាល់ដើម្បីចូលទៅប្រើប្រាស់ (Access ID)" មានន័យដូចខាងក្រោម៖

ក. លេខកាត ATM របស់លោកអ្នក / លេខកាតឥណពន្ធរបស់លោកអ្នក ឬ

ខ. លេខកាតឥណទានរបស់លោកអ្នក ឬ

គ. លេខអត្តសញ្ញាណសម្រាប់ចូលទៅប្រើប្រាស់ផ្សេងណាមួយទៀតដែលបានផ្តល់ជូនលោកអ្នកដោយធនាគារ RHB។

១.២ "គណនី" មានន័យថាជាគណនីណាមួយ ឬច្រើនរបស់លោកអ្នកដែលមាននៅធនាគារ RHB ដែលរួមមានគណនីសន្សំ គណនីឥណទាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីកម្ចី ឬគណនីណាមួយ ដែលអាចចូលទៅប្រើប្រាស់តាមរយៈសេវាធនាគារអ៊ីនធើណែត និង/ឬ សេវាធនាគារចល័តតាមគេហទំព័រដូចដែលបានកំណត់ធនាគារ RHB តាមពេលវេលាជាក់ស្តែង។

១.៣ "កម្មវិធី" សំដៅលើកម្មវិធីដែលត្រូវបានតម្លើងក្នុងឧបករណ៍អេឡិចត្រូនិចចល័តរបស់អ្នកប្រើប្រាស់ យោងទៅតាមការផ្លាស់ប្តូរចាំបាច់ដែលបានធ្វើឡើងក្នុងពេលកំពុងបង្កើតកម្មវិធី និងដូចដែលបានកែប្រែដោយខចែង និងលក្ខខណ្ឌនេះ។

១.៤ "ATM" មានន័យថាជាម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិណាមួយរបស់ធនាគារ RHB ដែលមាននៅកន្លែងណាមួយក៏ដោយ។

១.៥ "លេខសម្ងាត់ ATM" មានន័យថាជាលេខអត្តសញ្ញាណផ្ទាល់ខ្លួនរបស់លោកអ្នកដែលលោកអ្នកបានជ្រើសរើសតាមរយៈ ATM ណាមួយ យោងទៅតាមនីតិវិធីទទួលយកមកប្រើប្រាស់នូវសេវាកម្ម ATM។

១.៦ "ថ្ងៃធ្វើការ" មានន័យថាថ្ងៃណាមួយក៏ដោយដែលធនាគារ RHB បើកដំណើរការក្នុងប្រទេសកម្ពុជា។

១.៧ "ខ្លឹមសារ" មានន័យថាជាឯកសារ ព័ត៌មាន ក្រាហ្វិច អត្ថបទ រូបភាព តំណភ្ជាប់ ការផ្សាយពាណិជ្ជកម្ម និងទិន្នន័យដែលលេចឡើង ឬមាននៅក្នុងគេហទំព័រ។

១.៨ "CVV២/CVC២" មានន័យថាជាលេខបីខ្ទង់ដែលបានកំណត់នៅខាងក្រោយកាតឥណទាន/ឥណពន្ធ ធនាគារ RHB របស់លោកអ្នក។

១.៩ "ព័ត៌មានសម្គាល់ភិនភាគ" មានន័យថាជា លេខសម្គាល់ចូលទៅប្រើប្រាស់ ឈ្មោះអ្នកប្រើ លេខសំងាត់ ពាក្យសំងាត់ លេខសំងាត់ OTP លេខកូដសំងាត់ និងព័ត៌មានសម្គាល់ភិនភាគដែលមានលក្ខណៈស្រដៀងនេះ។

១.១០ "សេវាកម្មធនាគារអ៊ីនធើណែត" មានន័យថាជាផលិតផល និងសេវាកម្មដែលបានផ្តល់ជូនដោយធនាគារយើងខ្ញុំដល់លោកអ្នក តាមរយៈប្រព័ន្ធអ៊ីនធើណែតដោយគេហទំព័ររបស់ធនាគារយើងខ្ញុំ ដោយអនុលោមតាមខចែង និងលក្ខខណ្ឌនេះ ឬវិធាន និងបញ្ញត្តិដទៃទៀតណាមួយដែលបានកំណត់ដោយធនាគារ RHB។

១.១១ "តំណភ្ជាប់" មានន័យថាជាតំណភ្ជាប់មួយដែលត្រូវបានសម្គាល់ដោយពាក្យដែលបានគូសចំណាំ ពាក្យដែលមានពណ៌ផ្សេង និង/ឬក្រាហ្វិកមួយ (ឧទាហរណ៍ ដូចជាផ្លាកសញ្ញាសម្គាល់ពាណិជ្ជកម្ម ឬប៊ូតុង) លើគេហទំព័រដែល ផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់គេហទំព័រពីវត្តមាននៃតំណភ្ជាប់មួយទៅកាន់ទំព័រផ្សេងទៀតលើអ៊ីនធើណែត ឬរើលរ៉ាយវិបនៅលើទំព័រផ្សេងទៀតក្រៅពីគេហទំព័រ។

១.១២ "សេវាធនាគារចល័ត" មានន័យថាជាសេវាធនាគារអ៊ីនធើណែតដែលបានផ្តល់ជូនដោយធនាគារ RHB ជាសេវាកម្មដែលលោកអ្នកអាចចូលទៅប្រើប្រាស់តាមរយៈអ៊ីនធើណែត/GPRS/៣G ឬប្រព័ន្ធអេឡិចត្រូនិចណាមួយផ្សេងទៀតដែលបានអនុញ្ញាតដោយធនាគារ RHB អនុលោមតាមខចែង និងលក្ខខណ្ឌនេះ ឬវិធាន និងបញ្ញត្តិដទៃផ្សេងទៀតដែលបានកំណត់ដោយធនាគារ RHB។

១.១៣ "ឧបករណ៍អេឡិចត្រូនិចចល័ត" មានន័យថាជាឧបករណ៍អេឡិចត្រូនិច ឬឧបករណ៍ទំនាក់ទំនងដទៃទៀតដែលត្រូវបានប្រើសម្រាប់ចូលទៅប្រើប្រាស់សេវាធនាគារចល័ត។

១.១៤ "លេខសំងាត់ OTP" មានន័យថាជាកូដពិសេសដែលជាបន្សំនៃតួអក្សរនិងលេខ មានសុពលភាពសម្រាប់តែប្រតិបត្តិការមួយលើកប៉ុណ្ណោះ នៅពេលដែលលោកអ្នកបំពេញប្រតិបត្តិការដែលមានការប្រឈមហានិភ័យខ្ពស់ណាមួយ។ លេខសម្ងាត់ OTP ត្រូវបានផ្ញើរជាមួយគ្នានឹងលេខកូដសម្ងាត់តាមរយៈការផ្ញើរសារ (SMS) ទៅកាន់លេខទូរស័ព្ទដៃដែលបានប្រើដើម្បីចុះឈ្មោះរបស់លោកអ្នក។ លោកអ្នកត្រូវតែមានភាពប្រាកដប្រជាថាលេខកូដសំងាត់ដែលបានបង្ហាញ នៅក្នុងទំព័រសម្រាប់ធ្វើការបញ្ជាក់គឺដូចគ្នាបេះបិតជាមួយនឹងលេខកូដសំងាត់ដែលបានផ្ញើរតាមរយៈការផ្ញើរសារ (SMS) មុនពេលធ្វើការបញ្ចូលលេខសម្ងាត់ OTP របស់លោកអ្នកដើម្បីធ្វើការបញ្ចប់ប្រតិបត្តិការ។

១.១៥ "លេខសំងាត់" មានន័យថាជាបន្សំនៃតួអក្សរ និងលេខ ដែលបានជ្រើសរើសដោយលោកអ្នក ដែលមានលក្ខណៈពិសេសចំពោះលោកអ្នក ហើយមានតែលោកអ្នក និងប្រព័ន្ធកុំព្យូទ័ររបស់ RHB ប៉ុណ្ណោះដែលដឹង ហើយផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃភិនភាគអត្តសញ្ញាណចូល (SignOn ID) របស់លោកអ្នកនៅពេលណាក៏ដោយដែលលោកអ្នកចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត និង/ឬសេវាកធនាគារចល័ត ហើយលេខសំងាត់ជាមួយគ្នានឹង SingOn ID របស់លោកអ្នកត្រូវបានចាត់ទុកថាជាផ្នែកដទៃទៀតនៃហត្ថលេខាអេឡិចត្រូនិចរបស់លោកអ្នក។

១.១៦ "ការគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន(PFM)" មានន័យថាកម្មវិធីដែលបានផ្តល់ជូនអតិថិជនដែលមានសិទ្ធិដើម្បីជួយពួកគាត់ក្នុងការធ្វើផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន។ PFM អាចបែងចែកប្រតិបត្តិការ និង បន្ថែមគណនីពីស្ថាប័នច្រើនផ្សេងគ្នាក្នុងផ្ទាំងតែមួយដែលនឹងរួមបញ្ចូលការបង្ហាញនូវរូបភាពទិន្នន័យដូចជាលំហូរសាច់ប្រាក់ និន្នាការចំណាយ គោលបំណង ទ្រព្យសម្បត្តិគិតជាទឹកប្រាក់ និងការគ្រប់គ្រងបំណុល។

១.១៧ " ធនាគារ RHB" មានន័យថាជាធនាគារ RHB Indochina Bank Limited (លេខសម្គាល់ក្រុមហ៊ុន៖ ០០០០១៨១២) ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតមួយ ដែលបានចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងទទួលបានអាជ្ញាប័ណ្ណសម្រាប់ធ្វើការប្រតិបត្តិការធនាគារពីធនាគារជាតិនៃកម្ពុជា ហើយមានការិយាល័យចុះបញ្ជីនៅផ្ទះលេខ ២៦៣ ផ្លូវព្រះអង្គឌួង សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

១.១៨ "សេវាកម្ម" ឬ"សេវាកម្មទាំងឡាយ" មានន័យថាជាផលិតផល និងសេវាកម្មដែលបានផ្តល់ជូនដោយធនាគារយើងខ្ញុំតាមរយៈអ៊ីនធើណែតតាមគេហទំព័ររបស់ធនាគារយើងខ្ញុំ និង/ឬ សេវាធនាគារអ៊ីនធើណែតដែលបានផ្តល់ជូនដោយធនាគារ RHB ដែលលោកអ្នកអាចចូលទៅប្រើប្រាស់តាមរយៈអ៊ីនធើណែត/GPRS/៣G ឬប្រព័ន្ធអេឡិចត្រូនិចណាមួយដែលត្រូវបានអនុញ្ញាតដោយធនាគារ RHB អនុលោមតាមខចែង និងលក្ខខណ្ឌ ឬវិធាន និងបញ្ញត្តិណាមួយដទៃទៀតដែលបានកំណត់ដោយធនាគារ RHB។

១.១៩ " អ្នកផ្តល់សេវាកម្ម" មានន័យថាជាអ្នកផ្តល់សេវាកម្មចំពោះសេវាកម្ម PFM។

១.២០ "ពាក្យសំងាត់" មានន័យថាជាចង្កោមនៃតួអក្សរ និងលេខដែលបានជ្រើសរើសដោយលោកអ្នក ដែលមានលក្ខណៈពិសេសចំពោះលោកអ្នក ហើយមានតែលោកអ្នក និងប្រព័ន្ធកុំព្យូទ័ររបស់ធនាគារ RHB ប៉ុណ្ណោះ ដែលដឹង ហើយ

ពាក្យសំងាត់នេះនឹងបង្ហាញនៅលើអេក្រង់បន្ទាប់ពីលោកអ្នកបានវាយបញ្ចូលនូវ ឈ្មោះអ្នកប្រើសម្រាប់ចូលក្នុងប្រព័ន្ធរបស់លោកអ្នកប៉ុណ្ណោះ។ នេះជាមុខងារផ្ទៀងផ្ទាត់ភាពត្រឹមត្រូវទៅវិញទៅមកដែលត្រូវបានប្រើប្រាស់ដោយធនាគារ RHB ដើម្បីបញ្ជាក់ថាទំព័រចូលទៅប្រើប្រាស់ គឺពិតជាចេញពីគេទំព័ររបស់ធនាគារ RHB ពិតប្រាកដ មែន។

១.២១ "លេខកូដសុវត្ថិភាព" មានន័យថាជាលេខកូដប្រាំមួយខ្ទង់ដែលនឹងត្រូវបានបង្ហាញលើ 'ទំព័រសម្រាប់ធ្វើការបញ្ជាក់' ចំពោះប្រតិបត្តិការដែលមានហានិភ័យខ្ពស់ណាមួយ និងត្រូវបានផ្ញើជូនផងដែរតាមរយៈសារ (SMS) ទៅកាន់លេខទូរស័ព្ទដៃដែលបានប្រើដើម្បីចុះឈ្មោះរបស់លោកអ្នក។ លោកអ្នកត្រូវប្រាកដថា លេខកូដសំងាត់ដែល លេចឡើងលើទំព័រសម្រាប់ធ្វើការបញ្ជាក់ គឺដូចគ្នាបេះបិតទៅនឹងលេខកូដសុវត្ថិភាពដែលបានផ្ញើរតាមរយៈសារ (SMS)។

១.២២ "ខចែងស្តង់ដារ" មានន័យថាជាខចែង និងលក្ខខណ្ឌដែលមានស្រាប់របស់ធនាគារ RHB ដែលគ្រប់គ្រងគណនីផលិតផល សេវាកម្ម និងសម្ភារៈបរិក្ខារជាទូទៅរបស់ធនាគារ RHB មិនថាផលិតផល សេវាកម្ម ឬសម្ភារៈបរិក្ខារទាំងនេះត្រូវបានចូលទៅប្រើប្រាស់ ឬផ្តល់ជូនតាមរយៈ ឬក្នុងសេវាធនាគារអ៊ីនធើណែត និង/ឬសេវាធនាគារចល័ត ឬក៏អត់នោះទេ។

១.២៣ "ខចែង និងលក្ខខណ្ឌ" មានន័យថាជាខចែង និងលក្ខខណ្ឌទាំងឡាយសម្រាប់គ្រប់គ្រងការចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត និង/ឬសេវាធនាគារចល័ត ដូចដែលបានកែសម្រួលតាមពេលវេលាជាក់ស្តែង។

១.២៤ "ឈ្មោះអ្នកប្រើ" មានន័យថាជាឈ្មោះដែលផ្គុំឡើងដោយចង្កោមតួអក្សរដែលបានជ្រើសរើសដោយលោកអ្នក ដែលមានលក្ខណៈពិសេសចំពោះលោកអ្នក ហើយឈ្មោះអ្នកប្រើត្រូវបានចាត់ទុកថាជាផ្នែកមួយនៃហត្ថលេខាអេឡិចត្រូនិចរបស់លោកអ្នក និងជាមធ្យោបាយតែមួយគត់ដែលតាមរយៈនេះអនុញ្ញាតឲ្យប្រព័ន្ធសេវាធនាគារអ៊ីនធើណែតរបស់ធនាគារ RHB អាចធ្វើការកំណត់អត្តសញ្ញាណលោកអ្នក និងគណនីរបស់លោកអ្នកនៅពេលដែលលោកអ្នកចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត និង/ឬ សេវាធនាគារចល័ត។

១.២៥ ការប្រើប្រាស់ពាក្យ "ធនាគារយើង" "ធនាគាររបស់យើងខ្ញុំ" "RHB" និង "របស់ធនាគារយើងខ្ញុំ" មានន័យសំដៅដល់ធនាគារ RHB។

១.២៦ ការប្រើប្រាស់ពាក្យ "លោកអ្នក" "របស់លោកអ្នក" "ផ្ទាល់ខ្លួនលោកអ្នក" មានន័យថាជាអតិថិជនជាទីគោរពរបស់ធនាគារ RHB ដែលឈ្មោះរបស់គាត់មានគណនីមួយឬច្រើននៅធនាគារRHB និងជាបុគ្គលដែលប្រើប្រាស់ ឬត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ SignOn ID លេខសំងាត់សេវាធនាគារអ៊ីនធើណែត និង/ឬលេខសំងាត់សេវាធនាគារចល័ត ឬមធ្យោបាយចូលទៅប្រើប្រាស់ដទៃទៀតដូចដែលបានបង្កើត ឬអនុញ្ញាតដោយធនាគារ RHB។

១.២៧ "គេហទំព័រ" មានន័យថាជាគេហទំព័ររបស់ធនាគារ RHB នៅអាសយដ្ឋាន http://www.rhbgroup.com/cambodia

## ២. ចាប់ផ្តើមចុះឈ្មោះ និងចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត និង/ឬសេវាធនាគារចល័តរបស់ធនាគារ RHB

២.១ យោងទៅតាមខចែង និងលក្ខខណ្ឌដែលមាននៅក្នុងឯកសារនេះ សេវាធនាគារអ៊ីនធើណែត និង/ឬ សេវាធនាគារចល័តរបស់ RHB បានបើកឲ្យធ្វើការស្នើសុំ និងចុះឈ្មោះប្រើប្រាស់ជូនដល់អតិថិជនដែលមានគណនីសន្សំ/ចរន្ត និង/ឬ គណនីកាតឥណទាន/ឥណពន្ធ រួចជាស្រេចជាមួយនឹងធនាគារ RHB ហើយគណនីនេះមាន សុពលភាពនៅពេលណាក៏ដោយដែល**សេវាកម្ម**ត្រូវបានចូលទៅប្រើប្រាស់ និង/ឬប្រើប្រាស់ ដោយធ្វើការចុះឈ្មោះអនឡាញតែម្តងគត់នៅលើគេហទំព័រដើម្បីចាប់ផ្តើមប្រើប្រាស់**សេវាកម្ម**។ ទោះបីជាមានចែងដូចខាងលើក៏ដោយ តាមរយៈឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារយើងខ្ញុំ យើងខ្ញុំអាចធ្វើការបដិសេធនូវការចុះឈ្មោះចំពោះអតិថិជនដែលចូលទៅប្រើប្រាស់លើកដំបូងណាមួយ និង/ឬ ធ្វើការផ្លាស់លក្ខណៈវិនិច្ឆ័យសិទ្ធិប្រើប្រាស់ខាងលើដោយមិនចាំបាច់ផ្តល់ហេតុផលអ្វីទាំងអស់។

២.២ ចំពោះការចុះឈ្មោះអនឡាញតាមគេហទំព័រ ដើម្បីប្រើប្រាស់សេវាធនាគារអ៊ីនធើណែតរបស់ធនាគារ RHB គឺទាមទារឲ្យមានលេខសម្គាល់ចូលទៅប្រើប្រាស់ និងព័ត៌មានចាំបាច់ដូចជា លេខសម្ងាត់កាតATM/កាតឥណពន្ធ ឬ CVV២ របស់កាតឥណទាន ។ បន្ទាប់មក លោកអ្នកនឹងបង្កើតឈ្មោះអ្នកប្រើ លេខសំងាត់ និងពាក្យសំងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក ដើម្បីមានលទ្ធភាពចូលទៅប្រើប្រាស់សេវាកម្ម។

២.៣ នៅពេលដែលបានចុះឈ្មោះដោយជោគជ័យជាមួយនឹងសេវាធនាគារអ៊ីនធើណែតរបស់ RHB រួចរាល់ លោកអ្នកអាចប្រើប្រាស់ SingOn ID និងលេខសម្ងាត់ដូចគ្នានេះដើម្បីមានសិទ្ធិអាចចូលទៅប្រើប្រាស់សេវាធនាគារចល័ត។

២.៤ នៅពេលដែលធ្វើការចុះឈ្មោះ និងចូលទៅប្រើប្រាស់សេវាធនាគារចល័ត លោកអ្នកត្រូវបានចាត់ទុកថាបានអានយល់ និងព្រមព្រៀងក្នុងការចងកាតព្វកិច្ចដោយខចែង និងលក្ខខណ្ឌនេះ ហើយលោកអ្នកទទួលស្គាល់ និងលើសពីនេះទៀតទទួលយកហានិភ័យដែលអាចមានកើតឡើងទាំងអស់ពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការណាមួយលើប្រព័ន្ធអ៊ីនធើណែត/GPRS/ ៣G ឬប្រព័ន្ធអេឡិចត្រូនិចដទៃទៀតដែលបានអនុញ្ញាតដោយធនាគារ RHB។

២.៥ គ្រប់គណនីទាំងអស់របស់លោកអ្នក (រួមបញ្ចូលទាំងគណនីរួម) ដែលបានភ្ជាប់នឹងលេខសម្គាល់ចូលទៅប្រើប្រាស់នឹងត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិ និងអាចចូលទៅប្រើប្រាស់ក្រោមសេវាកម្ម តាមរយៈឈ្មោះអ្នកប្រើរបស់លោកអ្នក ដោយយោងទៅតាមចំនួនអតិបរមានៃគណនីដូចដែលបានបញ្ជាក់ដោយធនាគារ RHB តាមពេលវេលាជាក់ស្តែង។ លោកអ្នកអាចធ្វើការភ្ជាប់គណនីថ្មី ឬលុបចោលនូវគណនីដែលមានស្រាប់ពីឈ្មោះអ្នកប្រើរបស់លោកអ្នកដោយប្រើប្រាស់មុខងារ 'គ្រប់គ្រងគណនី' 'Manage Account' ដែលមាននៅក្នុងសេវាធនាគារអ៊ីនធើណែត។ ដូចនេះលោកអ្នកយល់ដឹង និងទទួលស្គាល់ថាលោកអ្នកនឹងគោរពយ៉ាងខ្ជាប់ខ្ជួននូវកាតព្វកិច្ចរបស់លោកអ្នកតាមប្រការ ៤ និងប្រការ ៦ នៅក្នុងខចែង និងលក្ខខណ្ឌនេះ ហើយថាធនាគារ RHB មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតដែលទទួលរងដោយលោកអ្នក ដែលកើតមានឡើងតាមវិធីណាក៏ដោយ ពីការមិនគោរពតាមកាតព្វកិច្ចរបស់លោកអ្នក។ បន្ថែមពីនេះទៀត ទោះបីជាមានអ្វីដែលបានចែងផ្ទុយពីនេះក៏ដោយ និងទោះបីជាលោកអ្នកមិនបានអនុលោមតាមនីតិវិធីចុះឈ្មោះប្រើប្រាស់សេវាកម្មក៏ដោយ ធនាគារ RHB មានសិទ្ធិ (ប៉ុន្តែមិនមែនជាកាតព្វកិច្ច) ក្នុងការហាមឃាត់ការចូលទៅប្រើប្រាស់របស់លោកអ្នករហូតដល់ពេលដែលធនាគារ RHB ទទួលបានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់គណនីរួមរបស់លោកអ្នក (ប្រសិនជាមាន) ចំពោះការមានសិទ្ធិចូលទៅប្រើ និងការប្រើប្រាស់សេវាកម្ម។

២.៦ លោកអ្នកត្រូវបានតម្រូវឲ្យផ្តល់ជូននូវព័ត៌មានដែលពិតប្រាកដ ត្រឹមត្រូវ មានបច្ចុប្បន្នភាព និងពេញលេញអំពីលោកអ្នក និងគណនីរបស់លោកអ្នកដែលបានរក្សាទុកនៅគេហទំព័រដទៃទៀត ហើយលោកអ្នកព្រមព្រៀងមិនក្លែងអត្តសញ្ញាណ ឬ ក្លែងព័ត៌មានគណនីរបស់លោកអ្នកឡើយ។ លោកអ្នកព្រមព្រៀងក្នុងការរក្សាព័ត៌មានពីគណនីរបស់លោកអ្នកឲ្យមានបច្ចុប្បន្នភាព និងត្រឹមត្រូវ ហើយធ្វើការជូនដំណឹងមកធនាគារយើងខ្ញុំក្នុងករណីដែលព័ត៌មានទាំងនេះត្រូវបានផ្លាស់ប្តូរ ហើយថាធនាគារRHB មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតដែលទទួលរងដោយលោកអ្នកដែលកើតមានឡើងតាមវិធីណាក៏ដោយ ពីការមិនគោរពតាមលក្ខខណ្ឌនេះរបស់លោក អ្នក។ បន្ថែមពីនេះទៀត ទោះបីជាមានអ្វីដែលបានចែងផ្ទុយពីនេះក៏ដោយ និងទោះបីជាលោកអ្នកមិនអនុលោមតាមនីតិវិធីចុះឈ្មោះប្រើប្រាស់សេវាកម្មក៏ដោយ ធនាគារ RHB មានសិទ្ធិ(ប៉ុន្តែមិនមែនជាកាតព្វកិច្ច) ក្នុងការហាមឃាត់ការចូលទៅប្រើប្រាស់របស់លោកអ្នករហូតដល់ពេលដែលធនាគារ RHB ទទួលបានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់គណនីរួមរបស់លោកអ្នក (ប្រសិនជាមាន) ចំពោះការចូលទៅប្រើប្រាស់សេវាកម្ម។

## ៣. **សេវាកម្ម** (រួមមាន សេវាផ្ទេរប្រាក់គ្រប់ប្រភេទ សេវាទូទាត់វិក្កយបត្រ ការបញ្ចូលប្រាក់បង់មុនជាថ្មី ពិនិត្យមើលសមតុល្យគណនី។ល។)

៣.១ លោកអ្នកត្រូវរក្សាទុកសាច់ប្រាក់គ្រប់គ្រាន់ដែលអនុញ្ញាតឲ្យធនាគារ RHB អាចបំពេញប្រតិបត្តិការកាត់ប្រាក់ចេញពីគណនីរបស់លោកអ្នក និងធ្វើការផ្ទេរប្រាក់តាមការស្នើសុំរបស់លោកអ្នក។

៣.១.១ សេវាកម្មផ្តល់ជូនដោយសេវាធនាគារអ៊ីនធើណែត RHB

- ផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន (រួមទាំងគណនីរួម)
- ផ្ទេរប្រាក់ទៅតតិយជន (ផ្ទេរតាមគណនីចំណូលចិត្ត & គណនីធម្មតា)
- ទូទាត់វិក្កយបត្រ (ទូទាត់តាមគណនីចំណូលចិត្ត & គណនីធម្មតា)
- សេវាបង់ប្រាក់មុន (ការដាក់ប្រាក់បង់មុនជាថ្មីតាមគណនីចំណូលចិត្ត & គណនីធម្មតា)
- ការផ្ទេរប្រាក់ដោយទូរគមន៍បរទេស
- ការផ្ទេរប្រាក់អន្តរធនាគារ (ផ្ទេរតាមគណនីចំណូលចិត្ត & គណនីធម្មតា)
- គណនីប្រាក់បញ្ញើមានកាលកំណត់ (ការដាក់ប្រាក់ ការដកប្រាក់មុនកាលកំណត់ ការដកប្រាក់)
- ការគ្រប់គ្រងមូលប្បទានប័ត្រ

  របាយការណ៍ហិរញ្ញវត្ថុអេឡិចត្រូនិច (គ្រប់គ្រងរបាយការណ៍អេឡិចត្រូនិច និងពិនិត្យមើលរបាយការណ៍តាមអេឡិចត្រូនិច)

៣.១.២ សេវាកម្មផ្តល់ជូនដោយសេវាធនាគារចល័តរបស់ RHB

- ផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួនរបស់លោកអ្នក (រួមទាំងគណនីរួម)
- ផ្ទេរប្រាក់ទៅភាគីទីបី (ផ្ទេរតាមគណនីចំណូលចិត្ត & គណនីធម្មតា)

- ទូទាត់វិក្កយបត្រ (ទូទាត់តាមគណនីចំណូលចិត្ត & គណនីធម្មតា)
- សេវាបង់ប្រាក់មុន (ការដាក់ប្រាក់បង់មុនជាថ្មីតាមគណនីចំណូលចិត្ត & គណនីធម្មតា)
- ការផ្ទេរប្រាក់តាមអន្តរធនាគារ (ផ្ទេរតាមគណនីចំណូលចិត្ត & គណនីធម្មតា)
- បញ្ចូលប្រាក់ទៅ E-Wallet

សម្គាល់៖

១. ការផ្ទេរប្រាក់តាមគណនីចំណូលចិត្តអាចធ្វើបានតែតាមរយៈសេវាធនាគារចល័តប៉ុណ្ណោះ ហើយការកំណត់ត្រូវបានធ្វើឡើងតាមរយៈសេវាធនាគារអ៊ីនធើណែត RHB

២. ការផ្ទេរប្រាក់តាមគណនីធម្មតា ការទូទាត់ និងការបញ្ចូលប្រាក់ជាថ្មី អាចធ្វើបានតែលើប្រព័ន្ធ iOS ប៉ុណ្ណោះ (iPhone & iPad) ។

៣.២ ប្រភេទប្រតិបត្តិការ និងកម្រិតកំណត់បច្ចុប្បន្ននៃសេវាធនាគារអ៊ីនធើណែត និង/ឬសេវាធនាគារចល័តដូចខាងក្រោម៖

| ប្រតិបត្តិការ | កម្រិតកំណត់ដើម (KHR) | កម្រិតអនុញ្ញាតឲ្យផ្លាស់ប្តូរ (KHR) | កម្រិតកំណត់ដើម (USD) | កម្រិតអនុញ្ញាតឲ្យផ្លាស់ប្តូរ (USD) |
|---|---|---|---|---|
| ផ្ទេរប្រាក់ទៅគណនីផ្ទាល់ខ្លួន | No limit | 0 - No limit | No limit | 0 - No limit |
| ផ្ទេរប្រាក់ទៅគណនីRHBដទៃទៀត | 40,000,000 | 0 - 200,000,000 | 10,000 | 0 - 50,000 |
| ផ្ទេរប្រាក់ទៅកាន់ធនាគារដទៃទៀត-IBG | 40,000,000 | 0 - 200,000,000 | 10,000 | 0 - 50,000 |
| ទូទាត់វិក្កយបត្រដោយប្រើគណនីផ្ទាល់ខ្លួន | No limit | 0 - No limit | No limit | 0 - No limit |
| ទូទាត់វិក្កយបត្រ | 2,000,000 | 0 – 4,000,000 | 500 | 0 - 1,000 |
| សេវាបញ្ចូលលុយទូរស័ព្ទ | 400,000 | 0 - 400,000 | 100 | 0 - 100 |
| ផ្ទេរប្រាក់ទៅក្រៅប្រទេស | 20,000,000 | 0 - 40,000,000 | 5,000 | 0 - 10,000 |
| សេវាទូទាត់រហ័ស | 40,000,000 | 0 - 40,000,000 | 10,000 | 0 - 10,000 |
| បញ្ចូលប្រាក់ទៅ E-Wallet | 10,000,000 | 0 - 10,000,000 | 2,500 | 0 - 2,500 |
| RHB Pay Anyone™ | 4,000,000 | 0 - 4,000,000 | 1,000 | 0 – 1,000 |

៣.៣ ការអនុវត្តកម្រិតកំណត់ខាងលើគឺតែងតែយោងទៅលើសាច់ប្រាក់ដែលមាននៅក្នុងគណនី (គណនីទាំងឡាយ) របស់លោកអ្នក ហើយធនាគារ RHB តាមរយៈនេះ រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកម្រិតកំណត់ដោយធ្វើការជូនដំណឹងដល់លោកអ្នកតាមពេលវេលាជាក់ស្តែង។

៣.៣.១ ធនាគារ RHB នឹងមិនទទួលខុសត្រូវចំពោះការពន្យារពេល ឬការខកខានក្នុងការផ្ទេរប្រាក់ណាមួយនោះទេ។ ជាអនុសាសន៍ សូមអនុញ្ញាតពីលោកអ្នកដើម្បីឲ្យធនាគារ RHB មានពេលវេលាគ្រប់គ្រាន់ក្នុងការ

ដំណើរការដោយជោគជ័យនូវការទូទាត់វិក្កយប័ត្រ/ ការផ្ទេរប្រាក់ និង/ឬជូនដំណឹងដល់លោកអ្នកពីបញ្ហា ឬការហាមឃាត់ក្នុងប្រតិបត្តិការដូចគ្នានេះ។ ធនាគារ RHB ទទួលខុសត្រូវចំពោះតែការផ្ទេរប្រាក់ដែលត្រូវបានបញ្ជាក់ផ្ទៀងផ្ទាត់ជាលាយលក្ខណ៍អក្សរជូនលោកអ្នកថាប្រតិបត្តិការបានជោគជ័យប៉ុណ្ណោះ។

៣.៣.២ ធនាគារ RHB មានសិទ្ធិក្នុងនាមជាតំណាងរបស់លោកអ្នក ប្រើប្រាស់តតិយជនឯករាជ្យណាមួយក្នុងការចេញសន្លឹកប័ណ្ណដែលធនាគារត្រូវសងប្រាក់ មូលប្បទានបត្រសាច់ប្រាក់ ឬសម្រេចប្រតិបត្តិការផ្ទេរប្រាក់ណាមួយ (ដូចជាការផ្ទេរប្រាក់តាម IBG និងសេវា RHB-PayPal) ហើយមិនទទួលខុសត្រូវសម្រាប់ការពន្យារពេល ការមិនបានផ្ទេរប្រាក់ ឬការមិនទទួលបានប្រាក់ផ្ទេរនេះដែលកើតឡើងដោយសារតែតតិយជនឯករាជ្យនោះឡើយ ។

៣.៣.៣ តាមរយៈឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារ RHB យើងខ្ញុំ ធនាគារកំណត់នូវលំដាប់លំដោយ ឬអាទិភាពនៃការផ្ទេរប្រាក់ដែលបានបញ្ជាប្រតិបត្តិការដោយលោកអ្នក ហើយតាមតាមរយៈឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារយើងខ្ញុំ ប្រើប្រាស់ឥណទានវិបារូបន៍ (ប្រសិនជាអាចធ្វើទៅបាន) ដើម្បីធ្វើប្រតិបត្តិការការផ្ទេរប្រាក់នេះជំនួសឲ្យគណនីដទៃទៀត (ប្រសិនជាមិនបានបញ្ជាក់ដោយលោកអ្នក) ហើយបន្ទាប់ពីនេះ អាចផ្ទេរប្រាក់ពីគណនីណាមួយរបស់លោកអ្នកដើម្បីទូទាត់ចំនួន ដែលបានដកលើសកំណត់ក្នុងគណនីចរន្តរបស់លោកអ្នក។ លើសពីនេះទៀត តាមរយៈសិទ្ធិសេរីភាពរបស់ខ្លួន ធនាគារ RHB នឹងធ្វើប្រតិបត្តិការផ្ទេរប្រាក់ ដើម្បីទូទាត់ការបង់ប្រាក់តាមកាតឥណទានទាំងអស់ដែលមិនទាន់បានបង់ ក្នុងករណីដែលកាតឥណទានរបស់លោកអ្នកលែងមានសុពលភាព។

៣.៣.៤ ការបញ្ជាចំពោះការផ្ទេរប្រាក់គឺយោងទៅតាមការកំណត់ណាមួយ ពេលបច្ចុប្បន្នដែលមានសុពលភាព ឬនាពេលបន្ទាប់ដែលមានសុពលភាពរវាងលោកអ្នក និងធនាគារ RHB ពាក់ព័ន្ធនឹងគណនីរបស់លោកអ្នក ឬការព្រមព្រៀងផ្សេងទៀតដែលធនាគារផ្តល់ជូនលោកអ្នក។ ជាពិសេស ធនាគារ RHB រក្សាសិទ្ធិក្នុងការៈ

៣.៣.៤.១ បដិសេធនៅពេលណាមួយក៏បានក្នុងការអនុវត្តនូវការបញ្ជាផ្ទេរប្រាក់របស់លោកអ្នក (មិនថាពាក់ព័ន្ធនឹងការផ្ទេរប្រាក់តែម្តងគត់ ឬការបញ្ជាប្រតិបត្តិការអចិន្ត្រៃយ៍/ការទូទាត់វិក្កយបត្រជាប្រចាំ ដោយមិនមានការបញ្ជាក់ហេតុផល និង/ឬ

៣.៣.៤.២ ដាក់កម្រិតកំណត់ ធ្វើការហាមឃាត់ឬ ដាក់លក្ខខណ្ឌលើការផ្ទេរប្រាក់របស់លោកអ្នក (មិនថាពាក់ព័ន្ធនឹងប្រភេទ រូបិយបណ្ណ គោលបំណង ចំនួនផ្ទេរ ឬទិដ្ឋភាពណាមួយនោះទេ) ដូចដែលបានតម្រូវដោយធនាគារ RHB ឬអាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធ ឬ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

## ៤.លេខសម្ងាត់ និងលក្ខណៈពិសេសដើម្បីរក្សាការសុវត្ថិភាពដទៃទៀត

៤.១ ដើម្បីលោកអ្នកអាចមានសិទ្ធិចូលទៅប្រើប្រាស់ សេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត លោកអ្នកត្រូវតែវាយបញ្ចូលនូវលេខកាត ATM/ លេខកាតឥណពន្ធ របស់លោកអ្នកជាមួយនឹង លេខសម្ងាត់កាត ATM/ លេខសម្ងាត់កាតឥណពន្ធ ឬលេខកាតឥណទានជាមួយនឹងលេខ CVV២ ឬ CVC២ ដូចដែលបានតម្រូវនៅពេលដែលលោកអ្នកចុះឈ្មោះប្រើប្រាស់សេវាកម្មជាលើកដំបូងតាមគេហទំព័រ www.rhbgroup.com/cambodia។

៤.១.១ អ្នកប្រើប្រាស់កាត ATM/កាតឥណពន្ធ

៤.១.១.១ ដើម្បីអាចឲ្យលោកអ្នកចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែតដើម្បីពិនិត្យមើលគណនី CA/SA ឬសមតុល្យកាតឥណទាន និងធ្វើប្រតិបត្តិការហិរញ្ញវត្ថុនានា លោកអ្នកត្រូវតែចុះបញ្ជីកាត ATM/ កាតឥណពន្ធ របស់លោកអ្នក នៅពេលដែលលោកអ្នក ចូលទៅក្នុងប្រព័ន្ធប្រើប្រាស់សេវាធនាគារអ៊ីនធើណែតជាលើកដំបូង។

៤.១.១.២ បន្ទាប់ពីមានការយល់ព្រមលើការចុះបញ្ជីកាត ATM/ កាតឥណពន្ធ របស់លោកអ្នក លោកអ្នកនឹងត្រូវបានតម្រូវឲ្យវាយបញ្ចូលនូវឈ្មោះអ្នកប្រើ និងលេខសំងាត់របស់លោកអ្នក។ នៅពេលដែលមានការយល់ព្រមលើលក្ខខណ្ឌដូចដែលបានរៀបរាប់ខាងលើ ហើយលោកអ្នកបានយល់ព្រមលើលើខចែង និងលក្ខខណ្ឌនេះ ការចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែតរបស់លោកអ្នកនឹងអាចដំណើរការបាន។

៤.១.២ អ្នកប្រើប្រាស់កាតឥណទាន

៤.១.២.១ ដើម្បីអាចឲ្យលោកអ្នកចូលទៅប្រើប្រាស់ និងប្រើប្រាស់សេវាធនាគារអ៊ីនធើណែត ដើម្បីមើលសមតុល្យគណនីកាតឥណទាន និងរបាយការណ៍សង្ខេបប្រតិបត្តិការរបស់លោកអ្នក លោកអ្នកត្រូវតែចុះបញ្ជីលេខកាតឥណទាន និងលេខ CVV២/CVC២ របស់លោកអ្នក នៅពេលដែលលោកអ្នកចូលទៅក្នុងប្រព័ន្ធដើម្បីប្រើប្រាស់សេវាធនាគារតាមអ៊ីនធើណែតជាលើកដំបូង។

៤.១.២.២ បន្ទាប់ពីមានការយល់ព្រមលើការចុះបញ្ជីកាតឥណទានរបស់លោកអ្នក លោកអ្នកត្រូវបានតម្រូវឲ្យវាយបញ្ចូលនូវឈ្មោះអ្នកប្រើ លេខសំងាត់ និងពាក្យសំងាត់របស់លោកអ្នក។ នៅពេលដែលមានការយល់ព្រមលើលក្ខខណ្ឌដូចដែលបានរៀបរាប់ខាងលើ ហើយលោកអ្នកបានយល់ព្រមលើលើខចែង និងលក្ខខណ្ឌនេះ ការចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែតរបស់លោកអ្នកនឹងអាចដំណើរការបាន។

៤.២ បន្ទាប់ពីនោះមក លោកអ្នកត្រូវបានតម្រូវឲ្យវាយបញ្ចូលតែឈ្មោះអ្នកប្រើ និងលេខសំងាត់ប៉ុណ្ណោះ សម្រាប់ការចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័តលើកក្រោយ។ ការផ្ទៀងផ្ទាត់ពាក្យសំងាត់អនុវត្តចំពោះតែការចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែតប៉ុណ្ណោះ។

៤.៣ បន្ទាប់ពីបញ្ចប់នីតិវិធីចុះឈ្មោះ និងដំណើរការដែលបានកំណត់ តាមរយៈសេវាធនាគារអ៊ីនធើណែត លោកអ្នកនឹងត្រូវបានអនុញ្ញាត ឲ្យទាញយកកម្មវិធីដើម្បីតម្លើងក្នុងទូរស័ព្ទដៃរបស់លោកអ្នក និងទទួលបានសិទ្ធិមិនផ្តាច់មុខ និងមិនអាចផ្ទេរបានក្នុងការប្រើប្រាស់កម្មវិធីនេះ ប៉ុន្តែផ្អែកលើនិងយោងទៅតាមការព្រមព្រៀងរបស់លោកអ្នកទៅនឹងលក្ខខណ្ឌដូចខាងក្រោម៖

៤.៣.១ លោកអ្នកមិនត្រូវប្រើប្រាស់កម្មវិធីដើម្បីគោលបំណងផ្សេង ក្រៅពីចូលទៅប្រើប្រាស់គណនីផ្ទាល់ខ្លួនរបស់លោកអ្នកតាមរយៈសេវាធនាគារចល័តនៅលើឧបករណ៍ចល័តរបស់លោកអ្នកនោះទេ

៤.៣.២ លោកអ្នកមិនត្រូវទាញយក ឬតម្លើងកម្មវិធីលើឧបករណ៍ចល័តដែលលោកអ្នកមិនមែនជាម្ចាស់កម្មសិទ្ធិ ឬមិនមានអ្នកគ្រប់គ្រងផ្តាច់មុខនោះទេ ហើយលោកអ្នកមិនត្រូវអនុញ្ញាត ឬឲ្យបុគ្គលណាមួយមានសិទ្ធិចូល

ទៅប្រើប្រាស់កម្មវិធីនេះទេ ឬទុកឧបករណ៍របស់លោកចោលដោយមិនប្រុងប្រយ័ត្នក្នុងឥរិយាបថមួយដែលឲ្យបុគ្គលណាមួយមានលទ្ធភាពចូលទៅប្រើប្រាស់កម្មវិធីនេះនោះទេ។

៤.៤ ដើម្បីធ្វើប្រតិបត្តិការហិរញ្ញវត្ថុ ឬផ្លាស់ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកៈ

៤.៤.១ តម្រូវឲ្យលោកអ្នកចុះបញ្ជីលេខទូរស័ព្ទដៃរបស់លោកអ្នក ជាមួយនឹងសេវាធនាគារអ៊ីនធើណែត RHB Now ក្នុងអំឡុងពេលចុះឈ្មោះដំបូង។ នេះជាដំណើរការដែលធ្វើឡើងតែម្តងប៉ុណ្ណោះ។ យ៉ាងណាមិញ ប្រសិនជាលោកអ្នកបានផ្លាស់ប្តូរលេខទូរស័ព្ទដៃរបស់លោកអ្នក លោកអ្នកត្រូវបានតម្រូវឲ្យចុះបញ្ជីលេខទូរស័ព្ទដៃរបស់លោកអ្នកសារជាថ្មីផងដែរ ដែលជាវិធានការសុវត្ថិភាពសេវាធនាគារអនឡាញ។

៤.៤.២ តម្រូវឲ្យលោកអ្នកធ្វើការផ្ទៀងផ្ទាត់លេខកូដសុវត្ថិភាព និងវាយបញ្ចូលនូវលេខសម្ងាត់ OTP ដែលត្រូវបានផ្ញើរជូនដោយស្វ័យប្រវត្តិទៅកាន់ទូរស័ព្ទដៃដែលបានចុះបញ្ជី និងបំពេញលក្ខខណ្ឌដែលបង្ហាញនៅទីនោះឲ្យបានចប់សព្វគ្រប់។

៤.៥ ប្រតិបត្តិការហិរញ្ញវត្ថុដោយប្រើប្រាស់សេវាធនាគារចល័ត ត្រូវបានអនុញ្ញាតចំពោះតែការផ្ទេរប្រាក់តាមគណនីចំណូលចិត្ត ដែលលោកអ្នកបានបង្កើតតាមរយៈសេវាធនាគារអ៊ីនធើណែតប៉ុណ្ណោះ។ លេខសម្ងាត់ OTP មិន អនុវត្តចំពោះសេវានេះទេ។

៤.៦ ធនាគារ RHB មានសិទ្ធិ នៅពេលណាមួយក៏ដោយ ក្នុងការធ្វើទុព្វលភាព ឬលុបចោលនូវព័ត៌មានសម្គាល់ភិនភាគរបស់លោកអ្នក ដោយជូនដំណឹងជាមុន ហើយលោកអ្នកអាចទទួលបានព័ត៌មានភ្លាមៗតាមតែអាចធ្វើទៅបាន។ ទុព្វលកម្ម ឬការលុបចោល នឹងត្រូវបានធ្វើឡើងប្រសិនបើព័ត៌មានសំងាត់ ឬសុវត្ថិភាពរបស់ព័ត៌មានសម្គាល់ភិនភាគរបស់លោកអ្នកត្រូវបានលេចធ្លាយ ឬត្រូវបានសង្ស័យថាត្រូវបានលេចធ្លាយ ឬប្រសិនបើសុវត្ថិភាព និងព័ត៌មានសំងាត់នៃផ្នែកណាមួយនៃ**សេវាកម្ម** ត្រូវបានគម្រាមកំហែងតាមមធ្យោបាយណាមួយក៏ដោយ។ យ៉ាងណាមិញ ធនាគារ RHB មិនមានកាតព្វកិច្ចក្នុងការបញ្ជាក់ពីហេតុផលជូនលោកអ្នកឡើយ និងមិនត្រូវទទួលខុសត្រូវ ឬទទួលរ៉ាប់រងចំពោះការខូចខាត ឬការបាត់បង់ណាមួយដែលលោកអ្នកអាចទទួលរងដែលជាលទ្ធផលនៃទុព្វលកម្ម ឬការលុបចោលនេះនោះទេ។

## ៥. ការជូនដំណឹង ការដាស់តឿន និងការផ្ញើរសារ

៥.១ ដើម្បីឲ្យលោកអ្នកទទួលបាននូវការដាស់តឿន និង/ឬ ការជូនដំណឹងពីធនាគារ RHB សម្រាប់ការទូទាត់វិក្កយបត្រ ការផ្ទេរប្រាក់ និងពេលវេលាមិនដំណើរការនៃប្រព័ន្ធ លោកអ្នកត្រូវធ្វើការជ្រើសរើសមធ្យោបាយដែលលោកអ្នកពេញចិត្តតាមរយៈការផ្ញើរសារ (SMS) សារសំងាត់ និង/ឬអ៊ីម៉ែលពីខាងក្រៅតាមរយៈឈ្មោះអ្នកប្រើរបស់លោកអ្នក ដោយប្រើប្រាស់មុខងារ 'ជូនដំណឹង (Notification)' ដែលមានអនឡាញ។

៥.២ លោកអ្នកអាចដាស់តឿនអ្នកទទួលផលពីការផ្ទេរប្រាក់ដែលលោកអ្នកបានធ្វើឡើង តាមរយៈការកំណត់នូវអ៊ីម៉ែល និងលេខទូរស័ព្ទដៃរបស់ពួកគេក្នុងអំឡុងពេល 'បន្ថែមបញ្ជីចំណូលចិត្ត' សម្រាប់មុខងារផ្ទេរប្រាក់ ឬ 'ផ្ទេរតាមគណនីធម្មតា' ដែលដាក់ឲ្យប្រើប្រាស់ដោយសេវាធនាគារតាមអ៊ីនធើណែត។

៥.៣ លោកអ្នកព្រមព្រៀងក្នុងការទទួលសារ និងការជូនដំណឹងពីធនាគារ RHB ដែលផ្ញើរទៅឧបករណ៍ចល័តដែលបានចុះបញ្ជីតាមរយៈអ៊ីនធើណែត និងសេវាធនាគារអ៊ីនធើណែត និងសេវាធនាគារចល័ត RHB Now។

៥.៤ ការឆ្លើយតបរបស់លោកអ្នកចំពោះសារ ឬការជូនដំណឹងពីសេវាធនាគារអ៊ីនធើណែត និងសេវាធនាគារចល័ត RHB Now ត្រូវបានចាត់ទុកថាជាការឆ្លើយតប/ការបញ្ជាដែលមានសុពលភាពទៅកាន់ធនាគារ RHB។

៥.៥ ធនាគារ RHB ត្រូវខិតខំប្រឹងប្រែងឲ្យបានសមស្របដើម្បីធានាភាពត្រឹមត្រូវ និងសុពលភាពនៃឯកសារ និងព័ត៌មានដែលបានផ្ញើរជូនដោយបុគ្គលិកដែលទទួលបានសិទ្ធិរបស់ធនាគារ RHB។ ធនាគារ RHB រក្សាសិទ្ធិគ្រប់ពេលវេលាក្នុងការផ្លាស់ប្តូរ កែប្រែ លុបចោល ឬបន្ថែមលើឯកសារ និងព័ត៌មានដែលបានផ្តល់ជូន ក្នុងលក្ខខណ្ឌដែលធនាគារ RHB បានផ្តល់សេចក្តីជូនដំណឹងដល់លោកអ្នក ២១(ម្ភៃមួយ) ថ្ងៃប្រតិទិនជាមុន។

## ៦.ការទទួលខុសត្រូវរបស់លោកអ្នកចំពោះសុវត្ថិភាព

៦.១ ដើម្បីធានាថាមានតែលោកអ្នកតែម្នាក់គត់ដែលអាចចូលទៅប្រើប្រាស់សេវាកម្មនេះ និងផ្តល់បញ្ជាប្រតិបត្តិការនានា លោកអ្នកត្រូវគោរពឲ្យបានខ្ជាប់ខ្ជួនតាមនីតិវិធីសុវត្ថិភាពដូចខាងក្រោមៈ

៦.១.១ ជាការទទួលខុសត្រូវរបស់លោកអ្នកតែម្នាក់ឯងគត់ ក្នុងការធានាថាព័ត៌មានសម្គាល់ភិនភាគរបស់លោកអ្នកត្រូវបានរក្សាទុកជាសំងាត់។ លោកអ្នកមិនត្រូវបង្ហាញព័ត៌មានសម្គាល់ភិនភាគណាមួយរបស់លោកអ្នកដល់អ្នកណាម្នាក់ឡើយ សូម្បីតែម្ចាស់គណនីរួមរបស់លោកអ្នក ឬបុគ្គលិកធនាគារណាម្នាក់ ឬអ្នក ផ្តល់ព័ត៌មានរបស់ធនាគារយើងខ្ញុំ។ ប្រសិនជាលោកអ្នកគិតថាព័ត៌មានសម្គាល់ភិនភាគណាមួយរបស់លោកអ្នកត្រូវបានដឹងដោយនរណាម្នាក់ លោកអ្នកត្រូវធ្វើការផ្លាស់ប្តូរវាតាមរយៈ**សេវាកម្ម** ភ្លាមៗតាមដែលអាចធ្វើទៅបាន។ ប្រសិនជាមិនអាចផ្លាស់ប្តូរបាន លោកអ្នកត្រូវជូនដំណឹងមកធនាគារយើងខ្ញុំ ភ្លាមៗដោយផ្ញើរអ៊ីម៉ែលទៅកាន់ ibanksupport.kh@rhbgroup.com ឬហៅទូរស័ព្ទមកកាន់លេខ (៨៥៥) ១៦ ៩៨៨ ២៨៨។

៦.១.២ លោកអ្នកមិនត្រូវអនុញ្ញាតឲ្យនរណាម្នាក់ផ្សេងទៀតធ្វើប្រតិបត្តិការ**សេវាកម្ម**ជំនួសឲ្យលោកអ្នក ទុកកុំព្យូទ័រចោលដោយមិនប្រុងប្រយ័ត្នខណៈពេលដែលលោកអ្នកបានចូលទៅប្រើប្រាស់**សេវាកម្ម** ឬរក្សាទុកនូវព័ត៌មានសម្គាល់ភិនភាគរបស់លោកអ្នកលើកម្មវិធីណាមួយលើកុំព្យូទ័រផ្ទាល់ខ្លួនរបស់លោកអ្នក (ដូចនេះព័ត៌មានដូចគ្នារបស់លោកអ្នកត្រូវបានបញ្ចូលដោយស្វ័យប្រវត្តិ នៅពេលដែលចូលទៅកាន់គេហទំព័រដោយមិនចាំបាច់តម្រូវឲ្យលោកអ្នក វាយបញ្ចូលព័ត៌មានសម្គាល់ភិនភាគលោកអ្នកនោះទេ)។ លោកអ្នកទទួលស្គាល់ និងព្រមព្រៀងថាធនាគារយើងខ្ញុំនឹងមិនទទួលខុសត្រូវ ឬទទួលរ៉ាប់រងចំពោះការបាត់បង់ ឬការខូចខាតណាមួយ (រួមបញ្ចូលទាំងមិនកំណត់ត្រឹមតែការបាត់បង់នូវមូលនិធិណាមួយ) ដែលបានកើតឡើង ឬទទួលរងដោយលោកអ្នក ឬភាគីដទៃណាមួយឡើយ ក្នុងករណីដែលព័ត៌មានណាមួយ ឬទាំងអស់របស់លោកអ្នក ឬមូលនិធិត្រូវបានគេចូលទៅប្រើប្រាស់ ឬ ត្រូវបានចាត់ចែងដោយតតិយជនទោះបីតាមរបៀបណាមួយក៏ដោយ ក្រោម**សេវាកម្ម**នេះ។

៦.១.៣ លើសពីនេះទៀត លោកអ្នកត្រូវទទួលខុសត្រូវចំពោះកម្មវិធីប្រឆាំងមេរោគ និងវិធានការសុវត្ថិភាពចំពោះកុំព្យូទ័រផ្ទាល់ខ្លួនរបស់លោកអ្នក ដើម្បីទប់ស្កាត់ការចូលទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតនូវប្រតិបត្តិការ និងគណនីរបស់លោកអ្នកតាមរយៈ**សេវាកម្ម**។

៦.១.៤ លោកអ្នកគួរតែត្រួតពិនិត្យមើលនូវសមតុល្យគណនីរបស់លោកអ្នកតាមកាលកំណត់ និង/ឬ ក្នុងពេលវេលាសមស្របបន្ទាប់ពីប្រតិបត្តិការណាមួយ ហើយអនុញ្ញាតឲ្យធនាគារយើងខ្ញុំដឹងភ្លាមៗពីភាពមិនប្រក្រតីផ្សេងៗ។ ប្រសិនបើលោកអ្នកលោកអ្នកដឹង ឬសង្ស័យថាមានប្រតិបត្តិការដែលមិនមានការអនុញ្ញាត ឬការចូលទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតនូវ**សេវាកម្ម** លោកអ្នកត្រូវតែជូនដំណឹងមកធនាគារយើងខ្ញុំភ្លាមៗដោយផ្ញើរអ៊ីម៉ែលមកកាន់ ibanksupport.kh@rhbgroup.com ឬហៅទូរស័ព្ទមកកាន់លេខ (៨៥៥) ១៦ ៩៨៨ ២៨៨។

៦.១.៥ លោកអ្នកត្រូវតែធានាថា កម្មវិធីដែលទាញយកសម្រាប់ប្រើប្រាស់សេវាធនាគារចល័ត គឺជាកម្មវិធីពិតប្រាកដ។

៦.១.៦ គ្រប់លេខសំងាត់ទាំងអស់ ត្រូវរក្សាការសំងាត់ឲ្យបានតឹងរ៉ឹង ហើយមិនត្រូវបង្ហាញដល់នរណាម្នាក់ឡើយ។

៦.១.៧ លោកអ្នកមិនត្រូវទុកកុំព្យូទ័រ/ឧបករណ៍ចល័តចោលដោយគ្មានការប្រុងប្រយ័ត្ននោះទេ ឬអនុញ្ញាតឲ្យបុគ្គលណាម្នាក់ចូលទៅប្រើប្រាស់កុំព្យូទ័រ/ឧបករណ៍ចល័តរបស់លោកអ្នកក្នុងឥរិយាបថមួយ ដែលគាត់អាចចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត កម្មវិធី ឬសេវាធនាគារចល័តរបស់លោកអ្នកនោះទេ ទោះបីជាមាន ឬគ្មានការព្រមព្រៀងពីលោកអ្នកក៏ដោយ។

៦.១.៨ នៅក្នុងករណីដែលលោកអ្នកបាត់បង់ ឬប្តូរ ឬចែករំលែកជាមួយអ្នកដទៃនូវការកាន់កាប់ ឬការគ្រប់គ្រងឧបករណ៍ចល័តរបស់លោកអ្នក ឬឧបករណ៍ផ្សេងទៀតណាមួយដែលមានតម្លើងកម្មវិធីនេះ ឬប្រសិនបើលោកអ្នកមានហេតុផលក្នុងការជឿជាក់ថា មាននរណាម្នាក់បានចូលទៅប្រើប្រាស់គណនី របស់លោកអ្នកដោយប្រើប្រាស់កម្មវិធីនេះ លោកអ្នកត្រូវជូនដំណឹង និងបញ្ជាភ្លាមៗមកធនាគារ RHB ដើម្បីធ្វើទុព្វលភាពព័ត៌មានសម្គាល់ភិនភាគរបស់លោកអ្នកភ្លាមៗ ហើយដាក់កម្មវិធីជាថ្មីដើម្បីចុះឈ្មោះសម្រាប់សេវាធនាគារអ៊ីនធើណែត ដើម្បីឲ្យលោកអ្នកអាចចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត។

៦.១.៩ ប្រសិនជាទូរស័ព្ទដៃរបស់លោកអ្នកបាត់ ឬត្រូវបានលួច សូមរាយការណ៍ភ្លាមៗពីការទូទាត់ប្រាក់ដែលគ្មានការអនុញ្ញាតតាមរយៈ**សេវាកម្ម**នេះ ដែលជាលទ្ធផលការបាត់បង់ ឬការលួចទូរស័ព្ទដៃរបស់លោក អ្នក។

៦.២ ក្នុងករណីដែលមានការសង្ស័យថាមានប្រតិបត្តិការដែលគ្មានការអនុញ្ញាត ធនាគារយើងខ្ញុំអាចផ្អាកការចូលទៅប្រើប្រាស់**សេវាកម្ម**របស់លោកអ្នក រហូតដល់ព័ត៌មានសម្គាល់ភិនភាគរបស់លោកអ្នកត្រូវបានកំណត់។

## ៧.ពេលវេលាប្រតិបត្តិការ

៧.១ **សេវាកម្ម** នឹងមានដំណើរការ ២៤ ម៉ោង និងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ លើកលែងតែមានការកំណត់ផ្សេងនៅក្នុងខចែង និងលក្ខខណ្ឌនេះ ឬលើ**គេហទំព័រ**។

៧.២ **សេវាកម្ម**មួយចំនួន ឬទាំងអស់ដែលអាចត្រូវបានចូលទៅប្រើប្រាស់តាមរយៈ គេហទំព័រ/កម្មវិធីធនាគារចល័ត អាចមិនដំណើរការនៅពេលវេលាជាក់ស្តែងណាមួយយោងទៅតាមតម្រូវការថែទាំជាប្រចាំ ភាពមិនដំណើរការ ឬប្រព័ន្ធមានបញ្ហាមិនអាចដំណើរការបាន ការប្រើប្រាស់ប្រព័ន្ធច្រើនលើសលប់ និង/ឬកាលៈទេសៈដែលមិនអាចគ្រប់គ្រងបានដោយធនាគារយើងខ្ញុំ។ ធនាគារ RHB មិនធ្វើការធានាជូនថា **សេវាកម្ម** (ឬផ្នែកណាមួយនៃ**សេវាកម្ម**) ដែល ផ្តល់ជូនតាមរយៈគេហទំព័រ/កម្មវិធីធនាគារចល័ត នឹងដំណើរការគ្រប់ពេលវេលាដូចដែលបានកំណត់នៅទីនេះនោះទេ។ នៅក្នុងករណីដែលមិនដំណើរការ ឬមានការរអាក់ខានណាមួយក្នុង**សេវាកម្ម**នេះ (ឬផ្នែកណាមួយនៃ**សេវាកម្ម**) លោកអ្នកអាចផ្ញើរអ៊ីម៉ែលមកកាន់ ibanksupport.kh@rhbgroup.com ឬហៅទូរស័ព្ទមកកាន់លេខ (៨៥៥) ១៦ ៩៨៨ ២៨៨។ សូមចងចាំថាប្រតិបត្តិការធនាគារអាចត្រូវបានធ្វើឡើងតាមរយៈបណ្តាញផ្តល់សេវាកម្មផ្សេងទៀតរបស់យើងខ្ញុំ (ដូចជា សាខា ATM ។ល។)។

## ៨.បញ្ជាប្រតិបត្តិការ

៨.១ លោកអ្នកព្រមព្រៀងដោយមិនអាចកែប្រែបាន និងអនុញ្ញាតឲ្យធនាគារយើងខ្ញុំអនុវត្តតាមបញ្ជាប្រតិបត្តិការរបស់លោកអ្នក (ដោយរួមមានការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រ បញ្ឈប់បញ្ជាបង់ប្រាក់ ការពិនិត្យមើលគណនីនានា និងការពិនិត្យមើលគណនីរបស់លោកអ្នកដែលបានរក្សានៅគេហទំព័រដទៃ។ល។) តាមរយៈ **សេវាកម្ម** បន្ទាប់ពីលោកអ្នកបានចូលក្នុងប្រព័ន្ធដោយជោគជ័យដើម្បីប្រើប្រាស់**សេវាកម្ម** ហើយទទួលខុសត្រូវពេញលេញចំពោះបញ្ជាប្រតិបត្តិការនេះ និងជាពិសេសក្នុងការធានាពីភាពត្រឹមត្រូវ និងពេញលេញនៃបញ្ជាប្រតិបត្តិការ របស់លោកអ្នក និងព្រមទាំងធានាថាបញ្ជាប្រតិបត្តិការដូចគ្នានេះមិនត្រូវបានបញ្ជូនមកកាន់ធនាគារយើងខ្ញុំពីរដងនោះទេ។

៨.២ រាល់បញ្ជាប្រតិបត្តិការ ដែលបានធ្វើឡើងបន្ទាប់ពីចូលក្នុងប្រព័ន្ធដើម្បីប្រើប្រាស់**សេវាកម្ម** នៅពេលដែលបានទទួលដោយធនាគារយើងខ្ញុំ នឹងត្រូវបានអនុវត្តស្របតាមនីតិវិធី កម្រិតកំណត់ និងលក្ខខណ្ឌដែលបានកំណត់ដោយធនាគារយើងខ្ញុំ និងដោយច្បាប់ជាធរមានតាមពេលពេលវេលាជាក់ស្តែង។ ធនាគារយើងខ្ញុំអាចពន្យារ ឬបដិសេធក្នុងការអនុវត្ត ឬកំណត់អាទិភាពនៃ ឬអនុវត្តបញ្ជាប្រតិបត្តិការណាមួយ ដោយមិនចាំបាច់មានការជូនដំណឹងជាមុន និងតាមឆន្ទានុសិទ្ធិរបស់ធនាគារយើងខ្ញុំ នៅពេលណាមួយក៏ដោយ ដោយមិនចាំបាច់ផ្តល់ហេតុផលណាមួយជូនលោកអ្នកឡើយ។ សូមចងចាំថាប្រតិបត្តិការមួយចំនួនអាចធ្វើទៅបាន តែក្នុងពេលម៉ោងធ្វើការធម្មតារបស់ធនាគារតែប៉ុណ្ណោះ ហើយអាចប្រើពេលវេលាប៉ុន្មានថ្ងៃធ្វើការដើម្បីបំពេញ ទោះបីជាមានការបន្ថែមម៉ោងប្រតិបត្តិការរបស់**សេវាកម្ម**ក៏ដោយ។

៨.៣ រាល់បញ្ជាប្រតិបត្តិការ ដែលបានធ្វើឡើងបន្ទាប់ពីបានចូលដោយជោគជ័យទៅក្នុងប្រព័ន្ធដើម្បីប្រើប្រាស់**សេវាកម្ម** ត្រូវចងកាតព្វកិច្ចចំពោះលោកអ្នកនៅពេលដែលបានបញ្ជូនមកកាន់យើងខ្ញុំ ដោយមិនគិតថាតើបញ្ជាប្រតិបត្តិការនេះ ត្រូវបានធ្វើឡើងដោយលោកអ្នកឬបុគ្គលដទៃឡើយ មិនថាដោយមានការអនុញ្ញាតឬក៏អត់ និងមិនគិតពីកំហុសការបោកប្រាស់ ឬការបន្លំនោះទេ។ ធនាគារយើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយ

(ដោយរួមបញ្ចូលមិនកំណត់ត្រឹមតែការបាត់បង់នូវមូលនិធិ) ដែលទទួលរង ឬកើតមានឡើងចំពោះលោកអ្នកដែលជាលទ្ធផលនេះ៖

៨.៣.១ បញ្ជាប្រតិបត្តិការ ឬប្រតិបត្តិការណាមួយដោយគ្មានការអនុញ្ញាតដែលបានធ្វើឡើងដោយប្រើប្រាស់ព័ត៌មានសម្គាល់ភិនភាគរបស់លោកអ្នក ជាលទ្ធផលនៃការមិនគោរពតាមកាតព្វកិច្ចរបស់លោកអ្នកក្នុងប្រការ៦នៃខចែង និងលក្ខខណ្ឌនេះ

៨.៣.២ ការបដិសេធរបស់ធនាគារយើងខ្ញុំក្នុងការអនុវត្តបញ្ជាប្រតិបត្តិការណាមួយ ដែលបានផ្តល់ជូនមកយើងខ្ញុំក្រោមកាលៈទេសៈសង្ស័យ ឬមិនប្រក្រតី តាមការយល់ឃើញដាច់ខាតរបស់ធនាគារ RHB

៨.៣.២.១ ការអនុវត្តតាមបញ្ជាប្រតិបត្តិការដោយធនាគារយើងខ្ញុំ ដោយគ្មានការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និង/ឬភាពពេញលេញនៃបញ្ជាប្រតិបត្តិការនេះ ទោះបីជាធនាគារ RHB មានសិទ្ធិ តាមរយៈឆន្ទានុសិទ្ធិដាច់ខាតរបស់ខ្លួនក្នុងការសុំការបញ្ជាក់ផ្ទៀងផ្ទាត់ពីលោកអ្នកក៏ដោយ

៨.៣.២.២ ការមិនគោរពតាមប្រការណាមួយនៃខចែង ឬលក្ខខណ្ឌនេះ របស់លោកអ្នក ដោយរួមមានតែមិនកំណត់ចំពោះ សែកស្ពុយ ដែលបណ្តាលមកពីសាច់ប្រាក់មិនគ្រប់គ្រាន់ក្នុងគណនីរបស់លោកអ្នក បន្ទាប់ពីបានកាត់កងសោហ៊ុយ និងថ្លៃសេវាតាមប្រការ១១ នៃខចែង និងលក្ខខណ្ឌនេះ។

៨.៤ នៅពេលដែលលោកអ្នកបានធ្វើបញ្ជាប្រតិបត្តិការណាមួយ លោកអ្នកមិនអាចលុបចោល ឬកែប្រែបានឡើយ។ យ៉ាងណាមិញ តាមការស្នើសុំរបស់លោកអ្នក ធនាគារយើងខ្ញុំអាច តាមរយៈឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារយើងខ្ញុំ (ប៉ុន្តែមិនមែនជាកាតព្វកិច្ចនោះទេ) ព្រមព្រៀងក្នុងការដកមកវិញ លុបចោល បដិសេធ ឬមិនដូចនេះទេកែប្រែបញ្ជាប្រតិបត្តិការណាមួយរបស់លោកអ្នក។ រាល់ថ្លៃចំណាយ និងថ្លៃសេវាដែលកើតមានឡើងដោយធនាគារយើងខ្ញុំក្នុងការអនុវត្តតាមការស្នើសុំនេះដោយលោកអ្នកគឺជាបន្ទុករបស់លោកអ្នក ហើយអាចត្រូវបានកាត់កងពីគណនីរបស់លោកអ្នកនៅធនាគារ RHB ប្រសិនជាអាចធ្វើទៅបាន។

៨.៥ វាជាការទទួលខុសត្រូវរបស់លោកអ្នកក្នុងការផ្តល់ដំណឹងមកធនាគារយើងខ្ញុំភ្លាមៗ៖

៨.៥.១ នៅពេលទទួលបានទិន្នន័យ ឬព័ត៌មានដែលមិនពេញលេញ មិនពិត ឬមិនត្រឹមត្រូវពីធនាគារយើងខ្ញុំនូវបញ្ជាប្រតិបត្តិការ ប្រតិបត្តិការ ឬការប្រើប្រាស់ណាមួយ និងទាំងអស់ក្រោម**សេវាកម្មនេះ។**

៨.៥.២ នៅពេលដែលទទួលបានទិន្នន័យ ឬព័ត៌មានណាមួយដែលមិនមានគោលបំណងផ្ញើរជូនលោកអ្នក លោកអ្នកត្រូវលុបចោលនូវទិន្នន័យ ឬព័ត៌មាននេះភ្លាមៗ និងមិនត្រូវរក្សាទុក (ឬចម្លងទុកនោះទេ)។

៨.៥.៣ នៅពេលដែលបានដឹង ឬនៅពេលដែលលោកអ្នកសង្ស័យ ឬមានហេតុផលក្នុងការជឿជាក់ថាការបញ្ជាណាមួយ ត្រូវបានធ្វើដោយលោកអ្នកមិនត្រូវបានទទួលដោយធនាគារយើងខ្ញុំ ឬមិនត្រឹមត្រូវដែលរួមបញ្ចូលដោយមិនកំណត់ត្រឹមតែការបង់ប្រាក់ដោយច្រឡំ ដោយបន្លំ ឬដោយមិនមានការអនុញ្ញាត ឬការផ្ទេរប្រាក់ពី ឬទៅកាន់គណនីរបស់លោកអ្នក។

## ៩. សិទ្ធិ និងកាតព្វកិច្ចរបស់តតិយជន

៩.១ លោកអ្នកអាចត្រូវការសេវាកម្មពី និង/ឬ កម្មវិធីទន់ (software) ដែលបានផ្តល់ជូនដោយតតិយជន ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារយើងខ្ញុំ ដើម្បីអាចចូលទៅប្រើប្រាស់ និងដំណើរការសេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត។ នៅក្នុងករណីនេះ លោកអ្នកយល់ដឹង និងព្រមព្រៀងដូចខាងក្រោម៖

៩.១.១ លោកអ្នកទទួលខុសត្រូវដោយខ្លួនឯងតែម្នាក់គត់ និងមិនត្រូវតាមរយៈមធ្យោបាយណាមួយ តម្រូវឲ្យធនាគារយើងខ្ញុំទទួលខុសត្រូវ ឬទទួលរ៉ាប់រងចំពោះសេវាកម្មណាមួយនិង/ឬកម្មវិធីទន់ដែលលោកអ្នកប្រើប្រាស់ដើម្បី អាចចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារយើងខ្ញុំនោះទេ

៩.១.២ លោកអ្នកទទួលខុសត្រូវដោយខ្លួនឯងតែម្នាក់គត់ ក្នុងការធានាថាកម្មវិធីទន់ដែលត្រូវបានផ្តល់ជូន លោកអ្នកមានដំណើរការលើកុំព្យូទ័រ ប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ណាមួយ ដែលតាមរយៈនេះលោកអ្នកអាចចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត ឬសេវាធនាគារចល័ត នឹងត្រូវគ្នាជាមួយនឹងកម្មវិធីទន់ណាមួយផ្សេងទាំងអស់លើកុំព្យូទ័រនោះ ឬអ្នកផ្តល់សេវាដទៃទៀតលើឧបករណ៍នោះ

៩.១.៣ លោកអ្នកត្រូវបានចងកាតព្វកិច្ចជាមួយនឹងខចែង និងលក្ខខណ្ឌដែលកំណត់ដោយសេវាកម្មនោះ និង/ឬកម្មវិធីទន់នោះដូចដែលបានរៀបរាប់ខាងលើដែលបានប្រើប្រាស់ដោយលោកអ្នកដើម្បីចូលទៅប្រើសេវាធនាគារអ៊ីនធើណែត ឬសេវាធនាគារចល័តដោយមិនមានឧបាស្រ័យណាមួយចំពោះធនាគារយើងខ្ញុំនោះទេ

៩.១.៤ ធនាគារយើងខ្ញុំនឹងមិនទទួលខុសត្រូវ ឬទទួលរ៉ាប់រងចំពោះការបាត់បង់ ឬការខូចខាត ឬថ្លៃសេវា ឬការចំណាយដទៃដែលអាចកើតមានឡើងចំពោះលោកអ្នក ដោយសារការប្រើប្រាស់របស់លោកអ្នកនូវសេវាកម្មនេះ និង/ឬកម្មវិធីទន់ដែលបានរៀបរាប់ខាងលើឡើយ។

៩.២ លោកអ្នកយល់ដឹងថាការចូលទៅប្រើប្រាស់គេហទំព័រ ឬសេវាធនាគារអ៊ីនធើណែត ឬសេវាធនាគារចល័តនឹងត្រូវធ្វើឡើងតាមរយៈអ្នកផ្តល់សេវាកម្មអ៊ីនធើណែត អ្នកផ្តល់ប្រព័ន្ធបណ្តាញ ឬអ្នកផ្តល់សេវាប្រព័ន្ធបណ្តាញទំនាក់ទំនង ឬអ្នកផ្តល់សេវាដទៃទៀត នៅក្នុងប្រទេសដែលសេវាកម្មនេះត្រូវបានចូលទៅប្រើប្រាស់ ហើយក្នុងករណីនេះ ការចូលទៅប្រើប្រាស់នឹងត្រូវយោងទៅតាម និងគ្រប់គ្រងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ប្រទេសនោះ និងខចែង និងលក្ខខណ្ឌទាំងឡាយណាដែលបានកំណត់ដោយអ្នកផ្តល់សេវាអ៊ីនធើណែត អ្នកផ្តល់ប្រព័ន្ធបណ្តាញ ឬអ្នកផ្តល់សេវាប្រព័ន្ធបណ្តាញទំនាក់ទំនងដែលពាក់ព័ន្ធ ឬអ្នកផ្តល់សេវាដទៃទៀត។

៩.៣ ធនាគារយើងខ្ញុំមិនធានានូវសុវត្ថិភាព និងការសំងាត់នៃព័ត៌មានដែលបានបញ្ជូនតាមរយៈអ្នកផ្តល់សេវាអ៊ីនធើណែត អ្នកផ្តល់ប្រព័ន្ធបណ្តាញ ឬអ្នកផ្តល់សេវាប្រព័ន្ធបណ្តាញទំនាក់ទំនង ឬប្រព័ន្ធដែលស្រដៀងគ្នាណាមួយក្នុងយុត្តាធិការណាមួយ តាមរយៈសេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត។ បន្ថែមពីលើនេះទៀត លោកអ្នកទទួលយក និងព្រមព្រៀងថាធនាគារយើងខ្ញុំមិនមានការទទួលខុសត្រូវចំពោះភាពមិនដំណើរការ ឬការខូចប្រព័ន្ធអេឡិចត្រូនិច មេកានិច ទិន្នន័យ មេរោគកុំព្យូទ័រ កំហុស ឬបញ្ហាដែលបណ្តាលមកពីសេវាកម្មដែលបានផ្តល់ជូន

ដោយអ្នកផ្តល់សេវាអ៊ីនធើណែត អ្នកផ្តល់ប្រព័ន្ធបណ្តាញ ឬអ្នកផ្តល់សេវាប្រព័ន្ធបណ្តាញទំនាក់ទំនងដែលពាក់ព័ន្ធ ឬ អ្នកផ្តល់សេវាដទៃទៀត។

៩.៤ តាមពេលវេលាជាក់ស្តែង និងតាមរយៈឆន្ទានុសិទ្ធិតែមួយគត់និងដាច់ខាតរបស់ខ្លួន ធនាគារ RHB យើងខ្ញុំ នឹងបង្ហាញផលិតផល ឬសេវាកម្មមួយចំនួនរបស់តតិយជនក្នុង**គេហទំព័រ** ឬ តំណភ្ជាប់ទៅកាន់គេហទំព័ររបស់តតិយជននេះនៅក្នុង**គេហទំព័រ**របស់ធនាគារយើងខ្ញុំ។ ខណៈពេលដែលធនាគារ RHB នឹងព្យាយាមក្នុងធានានូវគុណភាព និងស្តង់ដារអប្បបរមា ចំពោះគ្រប់ផលិតផល និងសេវាកម្មទាំងអស់ដែលបានផ្តល់ជូនតាមរយៈ**គេហទំព័រ** និងកម្មវិធីធនាគារចល័តរបស់យើងខ្ញុំ តែដោយហេតុផលថាលោកអ្នកទិញផលិតផល ឬសេវាកម្មនេះដោយផ្ទាល់ពី តតិយជនដែលពាក់ព័ន្ធ ធនាគារយើងខ្ញុំមិនអាចធ្វើការអះអាង ឬធានានូវប្រវត្តិកេរ្តិ៍ឈ្មោះនៃតតិយជននោះ និង/ឬ គុណភាព ឬស្តង់ដារនៃផលិតផល ឬសេវាកម្មរបស់ពួកគេនោះទេ។

៩.៥ លោកអ្នកត្រូវជួសជុលការខូចខាត ការពារ និងធានាឲ្យធនាគារយើងខ្ញុំរួចផុតពីរាល់បណ្តឹង ការទាមទារ សាលក្រម ការខូចខាត ការចំណាយ ការបាត់បង់ ការចាយវាយណាមួយ (ដោយរួមមានថ្លៃសោហ៊ុយប្រឹក្សាច្បាប់) និងការទទួលខុសត្រូវដទៃទៀតដែលកើតមានពីការរំលោភបំពាន និង/ឬ ការប្រព្រឹត្តផ្ទុយ និង/ឬ ការមិនអនុលោមតាមបញ្ញត្តិណាមួយនៃប្រការ៩នេះនោះទេ។

## ១០. សម្ភារៈបរិក្ខារ និងកម្មវិធីទន់

១០.១ លោកអ្នកព្រមព្រៀងផងដែរថា លោកអ្នកទទួលខុសត្រូវតែម្នាក់ឯងគត់ចំពោះកុំព្យូទ័រ ប្រព័ន្ធ ឬឧបករណ៍ដទៃទៀតរបស់លោកអ្នកដែលលោកអ្នកប្រើប្រាស់ ដើម្បីចូលទៅសេវាធនាគារអ៊ីនធើណែត ដោយរួមមានមិនកំណត់ត្រឹមតែការថែទាំ ប្រតិបត្តិការ និងការអនុញ្ញាតឲ្យប្រើប្រាស់កុំព្យូទ័រ ប្រព័ន្ធ ឬឧបករណ៍ដទៃទៀត ហើយលោកអ្នកមានកាតព្វកិច្ចក្នុងការអនុលោមតាមលក្ខខណ្ឌណាមួយ ដែលបានកំណត់ដោយធនាគារយើងខ្ញុំ តាមពេលវេលា ជាក់ស្តែងពាក់ព័ន្ធនឹងកុំព្យូទ័រ ប្រព័ន្ធ ឬឧបករណ៍ដទៃរបស់លោកអ្នកដែលលោកអ្នកបានប្រើប្រាស់ដើម្បីចូលទៅប្រើសេវាធនាគារអ៊ីនធើណែត (ដោយរួមមានផ្នែកទន់ណាមួយដែលបានប្រើប្រាស់)។

១០.២ លោកអ្នកមិនត្រូវចូលទៅប្រើប្រាស់សេវាកម្មដោយប្រើប្រាស់កុំព្យូទ័រ ប្រព័ន្ធ ឬឧបករណ៍ដទៃទៀតណាមួយដែលមិនមែនជាកម្មសិទ្ធិរបស់លោកអ្នកទេ លើកលែងតែលោកទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ។ លោកអ្នកត្រូវធានាផងដែរថាកុំព្យូទ័រ ប្រព័ន្ធ ឬឧបករណ៍ដទៃទៀតណាមួយដែលលោកអ្នកប្រើប្រាស់ដើម្បីចូលទៅប្រើប្រាស់ សេវាធនាគារអ៊ីនធើណែតគួរតែត្រូវបានថែទាំបានត្រឹមត្រូវ ហើយមិនត្រូវមានមេរោគ ឬផ្អាកដំណើរការនោះទេ។ លោកអ្នកត្រូវធានាផងដែរថា កុំព្យូទ័រ ឬកុំព្យូទ័រយួរដៃរបស់លោកអ្នកត្រូវបានតម្លើងកម្មវិធីកម្ចាត់មេរោគចុងក្រោយបំផុត និងកម្មវិធីប្រឆាំងនឹងការតាមដានព័ត៌មានអ្នកប្រើប្រាស់ និងថាកម្មវិធីទាំងនេះត្រូវបានតម្លើង និងធ្វើបច្ចុប្បន្នភាពនូវកំណែប្រែចុងក្រោយបំផុត។ លោកអ្នកត្រូវធានាផងដែរថា លោកអ្នកបានទាញយកកម្មវិធីពីប្រភពដែលទុកចិត្តបាន ហើយជាកម្មវិធីពិតប្រាកដ ហើយលោកអ្នកត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះរាល់កម្មវិធីដែលបានទាញយក។

១០.៣ ឯកសារណាមួយដែលបានទាញយក ឬបើមិនដូច្នេះទេទទួលបានតាមរយៈការប្រើប្រាស់**សេវាកម្ម** ត្រូវបានធ្វើឡើងដោយការសម្រេចចិត្តនិងការទទួលខុសត្រូវរបស់លោកអ្នក ហើយលោកអ្នកទទួលខុសត្រូវតែម្នាក់ឯងគត់លើ

ការខូចខាតចំពោះប្រព័ន្ធកុំព្យូទ័ររបស់លោកអ្នក ឬការបាត់បង់ទិន្នន័យដែលជាលទ្ធផលនៃការទាញយកឯកសារនោះ។ មិនមានឧបករណ៍ ឬព័ត៌មានណាមួយ មិនថាដោយផ្ទាល់ ឬជាលាយលក្ខណ៍អក្សរនោះទេ ដែលបានទទួលបានដោយលោកអ្នកពីធនាគារ RHB ឬអ្នកផ្តល់សេវាកម្មតាមរយៈ ឬពី**សេវាកម្ម** នឹងបង្កើតការធានាណាមួយដែលមិនបានចែងជាក់លាក់នៅក្នុងខចែងទាំងនេះនោះទេ។

## ១១. ថ្លៃសោហ៊ុយ និងថ្លៃសេវា

១១.១ តាមពេលវេលាជាក់ស្តែង និងដោយមានការជូនដំណឹងជាមុន ធនាគារ RHB មានសិទ្ធិកំណត់ឲ្យបង់ថ្លៃសេវា និងថ្លៃសោហ៊ុយ ឬថ្លៃសេវា និងថ្លៃឈ្នួលដែលមានផ្សេង ចំពោះការចូលទៅប្រើប្រាស់**សេវាកម្ម** ឬផលិតផល និង សេវាកម្មណាមួយដែលបានផ្តល់ជូននៅលើ**គេហទំព័រ** ដោយអនុលោមតាមបញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬបទបញ្ជាផ្សេងទៀតដែលបានដាក់ចេញដោយអាជ្ញាធរពាក់ព័ន្ធ។ ការបន្តចូលទៅប្រើប្រាស់**សេវាកម្ម** ត្រូវបានចាត់ទុកជាការទទួលយករបស់លោកអ្នកក្នុងការបង់ថ្លៃសោហ៊ុយនិងថ្លៃសេវាទាំងនេះ។

១១.២ ថ្លៃសោហ៊ុយ និងថ្លៃសេវាដែលបានកំណត់ខាងលើពាក់ព័ន្ធតែនឹងការចូលទៅប្រើប្រាស់**សេវាកម្ម** ឬ **គេហទំព័រ** ឬផលិតផល ឬសេវាកម្មដែលបានផ្តល់តាមរយៈនោះតែប៉ុណ្ណោះ។ លោកអ្នកអាចទទួលខុសត្រូវផងដែរចំពោះថ្លៃសោហ៊ុយ ឬថ្លៃសេវាដទៃទៀតដែលបានកំណត់ដោយធនាគារ RHB ចំពោះប្រតិបត្តិការ និងបញ្ជាប្រតិបត្តិការដែលបានធ្វើឡើងក្រោម ឬស្របតាម**សេវាកម្មនេះ** (ដោយរួមមានសោហ៊ុយធនាគារ ថ្លៃឈ្នួលរដ្ឋបាល សោហ៊ុយទម្រង់ការ ការប្រាក់ ។ល។) ហើយដែលអាចបង់ជូនធនាគារយើងខ្ញុំតាមខចែងស្តង់ដារ ឬក្រោមកិច្ចព្រមព្រៀងខសន្យា លក្ខខណ្ឌ ឬនីតិវិធីជាធរមានដទៃផ្សេងទៀតដែលបានកំណត់ដោយធនាគារ RHB។

១១.៣ លោកអ្នកយល់ព្រមបង់ពន្ធទាំងអស់ អាករ ពន្ធប្រថាប់ត្រា និងថ្លៃឈ្នួលពីរដ្ឋាភិបាលដែលកើតឡើងពីការចូលទៅប្រើប្រាស់របស់លោកអ្នកនូវ**សេវាកម្ម** ឬ **គេហទំព័រ**។

១១.៤ សូមចងចាំថា ធនាគារ RHB មានសិទ្ធិក្នុងការកាត់កងដោយស្វ័យប្រវត្តិពីគណនីលោកអ្នកចំពោះរាល់សោហ៊ុយ និងថ្លៃសេវាសម្រាប់ការចូលទៅប្រើប្រាស់**សេវាកម្ម** និងថ្លៃសេវារដ្ឋាភិបាល ពន្ធ អាករ និង/ឬពន្ធប្រថាប់ត្រាណាមួយព្រមទាំងសោហ៊ុយ និងថ្លៃសេវាណាមួយដែលអាចត្រូវបង់ចំពោះប្រតិបត្តិការដែលបានធ្វើឡើងដោយលោកអ្នកតាមពេលវេលាជាក់ស្តែង ដែលមានបញ្ជាក់ក្នុងខចែង និងលក្ខខណ្ឌនេះ។ ធនាគារយើងខ្ញុំមានកាតព្វកិច្ចក្នុងការជូនដំណឹងដល់លោកអ្នក ឬទទួលការព្រមព្រៀងពីលោកអ្នកជាមុនចំពោះការដកប្រាក់ណាមួយដែលបានធ្វើឡើងដោយធនាគារយើងខ្ញុំ។

១១.៥ សូមចងចាំផងដែរថា នៅក្នុងករណីដែលគណនីរបស់លោកអ្នក ត្រូវបានដកលើសប្រាក់ដែលមាន ដែលជាលទ្ធផលនៃការអនុវត្តសិទ្ធិរបស់ធនាគារក្នុងដកប្រាក់ ដោយស្វ័យប្រវត្តិពីគណនីរបស់លោកអ្នក ចំនួនទឹកប្រាក់ដែលបានដកលើសប្រាក់ដែលមាននោះរួមបញ្ចូលនឹងការប្រាក់ និងសោហ៊ុយធនាគារ ថ្លៃរដ្ឋបាល និងថ្លៃឈ្នួលណាមួយផ្សេងទៀតដែលបានកំណត់ដោយធនាគារយើងខ្ញុំ គឺជាបំណុលដែលជំពាក់ ហើយត្រូវតែទូទាត់ជូនធនាគារយើងខ្ញុំ ដែលត្រូវអនុវត្តនូវអត្រាការប្រាក់ និងអត្រាផាកពិន័យជាទូទៅនៃផលិតផលទានវិបារូបន៍។

## ១២. ការហាមឃាត់លើការប្រើប្រាស់សេវាធនាគារតាមអ៊ីនធើណែត/សេវាធនាគារចល័ត

១២.១ ជាលក្ខខណ្ឌមួយ នៃការអនុញ្ញាតឲ្យប្រើប្រាស់**គេហទំព័រ**/កម្មវិធីធនាគារចល័ត លោកអ្នកសន្យាថានឹងមិនប្រើប្រាស់**គេហទំព័រ**/កម្មវិធី (ឬសេវាកម្ម ព័ត៌មាន ឬផលិតផលណាមួយដែលមាននៅទីនេះ) សម្រាប់គោលបំណងខុសច្បាប់ ឬមិនស្របច្បាប់ ឬបើមិនដូច្នេះទេត្រូវបានហាមឃាត់ដោយច្បាប់ ឬដោយខចែង និងលក្ខខណ្ឌនេះ។ លោកអ្នកមិនត្រូវប្រើប្រាស់**គេហទំព័រ**/ កម្មវិធីធនាគារចល័ត (ឬសេវាកម្ម ព័ត៌មាន ឬផលិតផលណាមួយដែលមាននៅទីនេះ) ក្នុងឥរិយាបថណាមួយដែលអាចបំផ្លាញ ធ្វើឲ្យមិនដំណើរការ ជាបន្ទុកធ្ងន់ធ្ងរ ផ្អាកដំណើរការ ឬខូចខាតដល់**គេហទំព័រ** ឬផ្នែករឹង ឬកម្មវិធី និងប្រព័ន្ធផ្នែកទន់ នីតិវិធីសុវត្ថិភាព ព័ត៌មាន/បណ្ដាញអ្នកផ្ដល់សេវាកម្ម ឬប្រតិបត្តិការដទៃ ឬរំខានដល់ការប្រើប្រាស់ និងការប្រើប្រាស់ដោយរីករាយរបស់ភាគីណាមួយទៅលើ**គេហទំព័រ**នោះទេ។ លោកអ្នកមិនត្រូវព្យាយាមចូលទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតនោះទេចំពោះគណនីណាមួយ (ក្រៅពីគណនីរបស់លោកអ្នក) ឬប្រព័ន្ធផ្នែករឹង និងផ្នែកទន់ នីតិវិធីសុវត្ថិភាព ព័ត៌មាន/បណ្ដាញអ្នកផ្ដល់សេវាកម្ម ឬប្រតិបត្តិការដទៃផ្សេងទៀតដែលភ្ជាប់ជាមួយនឹង**គេហទំព័រ**/កម្មវិធីធនាគារចល័ត តាមរយៈការលួចចូលទៅប្រើ ការលួចលេខសំងាត់ ឬមធ្យោបាយផ្សេងណាមួយនោះទេ។ លោកអ្នកមិនត្រូវទទួល ឬព្យាយាមទាញយកឯកសារ ឬព័ត៌មានណាមួយតាមរយៈមធ្យោបាយណាមួយដែលមិនមានបំណងផ្ដល់ជូនតាមរយៈ**គេហទំព័រ** ឬសេវាធនាគារតាមអ៊ីនធើណែត/សេវាធនាគារចល័តនោះទេ។

១២.២ បន្ថែមពីលើការហាមឃាត់ និងលក្ខខណ្ឌដែលបានរៀបរាប់ខាងលើចំពោះការអនុញ្ញាតប្រើប្រាស់ និងការចូលទៅប្រើប្រាស់របស់លោកអ្នកលើ គេហទំព័រ/កម្មវិធីធនាគារចល័ត លោកអ្នកមិនត្រូវកែប្រែ ចម្លង ចែកចាយ បញ្ជូន ប្រើប្រាស់ ឬបើមិនដូច្នេះទេធ្វើការពាក់ព័ន្ធនឹងផលិតផល សេវាកម្ម ព័ត៌មាន ឬខ្លឹមសារណាមួយនៃគេហទំព័រ/ កម្មវិធីធនាគារចល័តដោយមិនបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីធនាគារយើងខ្ញុំនោះទេ លើកលែងតែមានការអនុញ្ញាតជាក់លាក់ក្រោមខចែង និងលក្ខខណ្ឌនេះ។ បន្ថែមពីលើនេះទៀត លោកអ្នកមិនត្រូវបង្ហោះ ផ្ញើរ ឬបញ្ជូន ខ្លឹមសារណាមួយដែលមិនត្រូវបានអនុញ្ញាតនៅលើ ឬតាមរយៈគេហទំព័រ/កម្មវិធីធនាគារចល័ត ដែលរួមបញ្ចូលមិនកំណត់ត្រឹមតែ ខ្លឹមសារដែល (i) មិនស្របច្បាប់ មិនថ្លៃថ្នូរ, អាសអាភាស, បង្ខូចកេរ្តិ៍ឈ្មោះ, រំលោភភាពឯកជន ប្រមាថ ឬ ទាស់ចិត្តទាស់ភ្នែក (ii) "junk mail" "spam" សំបុត្រសម្រាប់ចែកចាយបន្ត ឬទម្រង់ផ្សេងទៀតនៃខ្លឹមសារ/ឯកសារដែលមិនត្រូវបានអនុញ្ញាត និង (iii) មានផ្ទុកកម្មវិធីមេរោគ ឬ ហ្វាល ឬកម្មវិធីដែលអាចបង្អាក់ ធ្វើឲ្យមិនដំណើរការ ជាបន្ទុកធ្ងន់ធ្ងរ ផ្អាកដំណើរការ ឬ ខូចខាតដល់គេហទំព័រ ឬ ប្រព័ន្ធផ្នែករឹង ឬផ្នែកទន់ នីតិវិធីសុវត្ថិភាព ព័ត៌មាន/បណ្ដាញអ្នកផ្ដល់សេវា ឬប្រតិបត្តិការផ្សេងទៀត។

១២.៣ នៅគ្រប់ពេលវេលាទាំងអស់ លោកអ្នកព្រមព្រៀងក្នុងការរក្សា និងទុកសាច់ប្រាក់គ្រប់គ្រាន់នៅក្នុងគណនីរបស់លោកអ្នកក្នុងគោលបំណងសម្រួលដល់ការស្នើសុំណាមួយដែលបានធ្វើឡើងអនុលោមតាមខចែង និងលក្ខខណ្ឌនេះ។

## ១៣. ម្ចាស់កម្មសិទ្ធលើសិទ្ធិកម្មសិទ្ធិបញ្ញា

១៣.១ លោកអ្នកត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ខ្លឹមសារដែលបានផ្ដល់ជូនលោកអ្នក តាមរយៈ**សេវាកម្ម**ប៉ុណ្ណោះទៅលើ**សេវាកម្ម**ដូចដែលបានផ្ដល់ជូនតាមរយៈខចែង និងលក្ខខណ្ឌនេះ។

១៣.២ ធនាគារយើងខ្ញុំជាម្ចាស់កម្មសិទ្ធិដាច់ណាត់ ហើយតាមរយៈនេះធ្វើការអះអាងមិនថាពេលបច្ចុប្បន្ន ឬក្នុងពេលអនាគតនោះទេ សិទ្ធិដែលបានចុះបញ្ជីកា និងមិនទាន់បានចុះបញ្ជីកា (ដោយរួមមានទាំងសិទ្ធិសីលធម៌) លើសេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត ខ្លឹមសារ កម្មវិធី និង**គេហទំព័រ** និងសិទ្ធិស្របច្បាប់ និងសិទ្ធិទទួលផល និងផលប្រយោជន៍ណាមួយ មិនថាលក្ខណៈណាមួយក៏ដោយដែលពាក់ព័ន្ធ ដែលត្រូវបានចែងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសទាំងអស់លើពិភពលោកសម្រាប់រយៈពេលដែលបានការពារ ជាមួយនឹងការបន្តជាថ្មី និងការបន្ថែមណាមួយផងដែរ។

១៣.៣ មិនមានអ្វីនៅក្នុងឯកសារនេះត្រូវបានចាត់ទុកថាផ្តល់អាជ្ញាប័ណ្ណដោយជាក់លាក់ ឬបង្កប់ន័យ (ឬសិទ្ធិដទៃទៀត) ដល់លោកអ្នកក្នុងការប្រើប្រាស់ ផលិតសារជាថ្មី ចម្លង ឬធ្វើការពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា ឬសិទ្ធិជាម្ចាស់កម្មសិទ្ធិស្របច្បាប់ណាមួយ ដែលបានកំណត់ក្នុងកថាខណ្ឌខាងលើ។ សេវាធនាគារតាមអ៊ីនធើណែត/សេវាធនាគារចល័ត និងសិទ្ធិដែលបានផ្តល់ជូនលោកអ្នក តាមខចែងនិងលក្ខខណ្ឌនេះ ត្រូវបានផ្តល់ជូនដល់លោកអ្នកសម្រាប់តែការចូលទៅប្រើប្រាស់ផ្ទាល់ខ្លួនលោកអ្នកប៉ុណ្ណោះ។ សិទ្ធិណាមួយ ដែលមិនត្រូវបានអនុញ្ញាតជាក់លាក់តាមខចែង និងលក្ខខណ្ឌនេះទេ ជាកម្មសិទ្ធិទាំងស្រុង និងផ្តាច់មុខរបស់ធនាគារ RHB។

១៣.៤ លោកអ្នកផ្តល់អាជ្ញាប័ណ្ណដល់ធនាគារ RHB និងអ្នកផ្តល់សេវាកម្មរបស់ធនាគារ នូវព័ត៌មាន ទិន្នន័យ លេខសំងាត់ ឯកសារ ឬខ្លឹមសារណាមួយ (ដែលជារួមត្រូវបានហៅថា "ខ្លឹមសារព័ត៌មានអតិថិជន") ដែលលោកអ្នកផ្តល់ជូនតាម រយៈ**សេវាកម្ម**។ ធនាគារ RHB និងអ្នកផ្តល់សេវាកម្មអាចប្រើប្រាស់ កែប្រែ បង្ហាញ ចែកចាយ និងបង្កើតឯកសារថ្មីដោយប្រើប្រាស់ខ្លឹមសារព័ត៌មានអតិថិជននេះដើម្បីផ្តល់សេវាកម្មជូនដល់លោកអ្នក។ តាមរយៈការបញ្ជូនខ្លឹមសារព័ត៌មានអតិថិជន លោកអ្នកព្រមព្រៀង ឬសន្យាដោយស្វ័យប្រវត្តិថា ម្ចាស់នៃខ្លឹមសារព័ត៌មានអតិថិជននេះបានព្រមព្រៀងជាក់លាក់ ដោយគ្មានកំណត់រយៈពេល និងដោយមិនចាំបាច់បង់ថ្លៃសេវាណាមួយថា ធនាគារ RHB និងអ្នកផ្តល់សេវាកម្មអាចប្រើប្រាស់ ខ្លឹមសារព័ត៌មានអតិថិជនសម្រាប់គោលបំណងដែលបានកំណត់ខាងលើ។ រវាងធនាគារ RHB និងអ្នកផ្តល់សេវាកម្ម ធនាគារ RHB ជាម្ចាស់កម្មសិទ្ធិនៃព័ត៌មានសំងាត់នៃគណនីរបស់លោកអ្នក។

១៣.៥ លោកអ្នកមិនត្រូវតាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈតតិយជនណាម្នាក់ក្តីប្រព្រឹត្ត ឬព្យាយាមក្នុងការប្រព្រឹត្តនៅសកម្មភាពរំលោភច្បាប់ ដោយរួមមានតែមិនកំណត់ចំពោះ ការបង្កើតហ្វ្រេមក្នុងគេហទំព័រ (framing) ឥតភ្ជាប់ដោយមិនមានការអនុញ្ញាត ផ្ញើរសារបោកប្រាស់ ប្រើ metatag និង/ឬប្រើកម្មវិធីលួចយកទិន្នន័យ ឬព័ត៌មានលើប្រព័ន្ធ អ៊ីនធើណែត។

១៣.៦ លោកអ្នកព្រមព្រៀងមិនលួចទិន្នន័យដើម្បីទៅផ្គុំសារជាថ្មី ឬ មិនផ្គុំសារឡើងវិញនូវបច្ចេកវិទ្យាណាមួយរបស់សេវាកម្ម ដោយរួមមានតែមិនកំណត់ចំពោះ កម្មវិធី Java applets ដែលពាក់ព័ន្ធនឹង**សេវាកម្ម**។

១៣.៧ តាមពេលវេលាជាក់ស្តែង ធនាគារ RHB អាចចេញសេចក្តីណែនាំ ឬបទបញ្ជាពាក់ព័ន្ធនឹងការប្រើប្រាស់ណាមួយលើសិទ្ធិកម្មសិទ្ធិបញ្ញា និងសិទ្ធិលើកម្មសិទ្ធិស្របច្បាប់ ដែលជាកម្មសិទ្ធិរបស់ធនាគារ RHB (ឬដល់អ្នកដែលបានចាត់តាំងរបស់ខ្លួន) ហើយលោកអ្នកត្រូវអនុលោមតាមសេចក្តីណែនាំ និងបទបញ្ជាទាំងអស់នោះ។

## ១៤. ការតំណាង និងការធានា

១៤.១ លើកលែងតែមានចែងជាក់លាក់នៅក្នុងឯកសារនេះ និងតាមកម្រិតដែលអនុញ្ញាតដោយច្បាប់ លោកអ្នកយល់ដឹង និងព្រមព្រៀងថា ការប្រើប្រាស់**សេវាកម្ម** និងរាល់ព័ត៌មានទាំងអស់ ផលិតផល និងខ្លឹមសារដទៃទៀត (រួមទាំងរបស់តតិយជន) ដែលបានរួមបញ្ចូល ឬអាចចូលទៅប្រើប្រាស់បានពី**សេវាកម្ម** គឺជាការទទួលខុសត្រូវរបស់លោក អ្នក។ **សេវាកម្ម**នេះ ត្រូវបានផ្តល់ជូនលើមូលដ្ឋាន "ដូចដែលមាន" និង"ដូចដែលដំណើរការ"។ ធនាគារយើងខ្ញុំ និងអ្នកផ្តល់សេវាកម្មធ្វើការបដិសេធជាក់លាក់មិនទទួលខុសត្រូវចំពោះការធានា ការអះអាង ការធានារ៉ាប់រង ឬការយល់ព្រម មិនថាដោយជាក់លាក់ ឬបង្កប់ន័យ ដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ដោយរួមមានតែមិនកំណត់ចំពោះការធានា សម្រាប់ដោះដូរបានលើទីផ្សារ ភាពស័ក្តិសមចំពោះគោលបំណងជាក់លាក់ណាមួយ ភាពត្រឹមត្រូវ គុណភាព ភាពគ្រប់គ្រាន់ សុវត្ថិភាព ភាពដំណើរទៅបាន ភាពអាចទុកចិត្តបាន ទាន់ពេលវេលា មិនរំលោភបំពានច្បាប់ និង/ឬ ភាពពេញលេញនៃផលិតផល សេវាកម្ម ព័ត៌មាន ខ្លឹមសារណាមួយ ឬអ្វីផ្សេងទៀត (ដោយរួមបញ្ចូលផលិតផល សេវាកម្ម ព័ត៌មាន ខ្លឹមសាររបស់តតិយជន) ដែលមាននៅក្នុង**គេហទំព័រ** ឬមានផ្តល់ជូនដល់លោកអ្នកក្រោម ឬអនុលោមតាមសេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័តឬ ខចែង និងលក្ខខណ្ឌនេះ ឬការបំពេញ ការប្រើប្រាស់ និងប្រតិបត្តិការនៃអ្វីដែលបានរៀបរាប់លើ។ ធនាគារ RHB និងអ្នកផ្តល់សេវាកម្មមិនធ្វើការធានាថា (i) **សេវាកម្ម**នឹងឆ្លើយតបតម្រូវការរបស់លោកអ្នកនោះទេ (ii) **សេវាកម្ម** នឹងមិនមានការរំខាន ទាន់ពេលវេលា មានសុវត្ថិភាព ឬមិនមានកំហុសឆ្គងនោះទេ (iii) លទ្ធផលដែលទទួលបានពីការប្រើប្រាស់**សេវាកម្ម**នឹងមានភាពត្រឹមត្រូវ ឬអាចទុកចិត្តបាននោះទេ (iv) គុណភាពនៃផលិតផល សេវាកម្ម ព័ត៌មាន ឬឯកសារសម្ភារៈណាមួយដែលបានទិញ ឬទទួលបានដោយលោកអ្នកតាមរយៈ**សេវាកម្ម**នឹងឆ្លើយតបនឹងសេចក្តីរំពឹងទុករបស់លោកអ្នកនោះទេ ឬ(v) កំហុសឆ្គងប្រព័ន្ធបច្ចេកវិទ្យានឹងត្រូវបានកែសម្រួលនោះទេ (vi) **សេវាកម្ម** នឹងមិនត្រូវបានផ្អាកដំណើរ បញ្ចប់ ឬលុបចោលដោយយោងទៅតាមហេតុផលណាមួយនោះទេ។

១៤.២ លោកអ្នកព្រមព្រៀងថាលោកអ្នកបានមិនបានពឹងផ្អែកលើការអះអាង ការធានា ឬការធានារ៉ាប់រងណាមួយដែលបានធ្វើឡើងដោយធនាគារយើងខ្ញុំនោះទេ លើកលែងតែការអះអាង ការធានា ឬការធានារ៉ាប់រងដែលបានបញ្ជាក់ជាក់លាក់ក្នុងខចែង និងលក្ខខណ្ឌនេះ។ ការអះអាង មិនថាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ដែលបានធ្វើឡើងដោយបុគ្គលិក ឬអ្នកតំណាងរបស់ធនាគារ RHB ត្រូវចាត់ទុកជាមោឃៈ និងមិនមានសុពលភាពផ្លូវច្បាប់ទេ ទោះតាមមធ្យោបាយណាក៏ដោយ។

## ១៥. ការទទួលខុសត្រូវ & ការធានាជួសជុលការខូចខាត

១៥.១ ធនាគារយើងខ្ញុំ និងអ្នកផ្តល់សេវាកម្ម ឬសាខាក្រុមហ៊ុនណាមួយរបស់ធនាគារយើងខ្ញុំ ឬរបស់អ្នកផ្តល់សេវាកម្មទាំងនោះ អ្នកផ្តល់គណនី ឬសាខាក្រុមហ៊ុនណាមួយរបស់ពួកគេធ្វើការទទួលខុសត្រូវតែចំពោះការបាត់បង់ និងខូចខាតដោយផ្ទាល់របស់លោកអ្នកដែលបណ្តាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរនិង/ឬកំហុសដោយចេតនារបស់យើងខ្ញុំប៉ុណ្ណោះ។ មិនមានករណីណា ដែលធនាគារយើងខ្ញុំ អ្នកផ្តល់សេវាកម្មរបស់ធនាគារយើងខ្ញុំ ឬ ឬសាខាក្រុមហ៊ុនណាមួយរបស់ធនាគារយើងខ្ញុំ ឬរបស់អ្នកផ្តល់សេវាកម្មទាំងនោះ អ្នកផ្តល់គណនី ឬសាខាក្រុមហ៊ុនណាមួយរបស់ពួកគេធ្វើការទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយ មិនថាដោយផ្ទាល់ ឬដោយប្រយោល ដើម្បីជាគំរូ ជាលទ្ធផល ដោយចៃដន្យ ជាការពិន័យទណ្ឌកម្ម ការបាត់បង់ ឬខូចខាតពិសេស ឬការបាត់បង់ប្រាក់ចំណូល

ប្រាក់ចំណេញ កេរ្តិ៍ឈ្មោះ ការប្រើប្រាស់ ទិន្នន័យ ឬការបាត់បង់ជាអរូបិយ៍ផ្សេងទៀត (ដោយរួមបញ្ចូលរបស់តតិយជនណាមួយផងដែរ) មិនខ្វល់ថាកើតឡើងតាមមធ្យោបាយណានោះទេ ហើយរាល់ការបាត់បង់ទាំងនេះមិនត្រូវបានរួមបញ្ចូលដូចដែលបានបញ្ជាក់នៅទីនេះ។

១៥.២ បញ្ញត្តិខាងលើនឹងមានសុពលភាពអនុវត្ត ទោះបីជាជាមានអង្គហេតុដែលថាធនាគារ RHB ឬអ្នកផ្តល់សេវាកម្មត្រូវបានជម្រាបពីភាពដែលអាចកើតមានឡើង នៃការខូចខាតទាំងនេះក៏ដោយ ដែលជាលទ្ធផលនៃ៖(i) ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់**សេវាកម្ម** (ii) ថ្លៃចំណាយក្នុងការទទួលបានទំនិញ និងសេវាកម្មជំនួស (iii) ផលិតផល ទិន្នន័យ ព័ត៌មានឬសេវាកម្មណាមួយដែលបានទិញ ឬបានទទួល ឬសារដែលបានទទួល ឬប្រតិបត្តិការដែលបានដំណើរការ តាមរយៈ ឬពី**សេវាកម្ម** (iv) ការចូលទៅប្រើប្រាស់ ឬធ្វើការផ្លាស់ប្តូរការបញ្ជូន ឬទិន្នន័យរបស់លោកអ្នក ដោយមិនមានការអនុញ្ញាត (v) សេចក្តីបញ្ជាក់ ឬការប្រព្រឹត្តរបស់អ្នកណាម្នាក់លើ**សេវាកម្ម** (vi) ការប្រើប្រាស់ អសមត្ថភាពក្នុងការប្រើប្រាស់ ការប្រើប្រាស់ដោយមិនមានការអនុញ្ញាត ការអនុវត្ត ឬ ការមិនអនុវត្តនៃ គេហទំព័រ អ្នកផ្តល់សេវាគណនីតតិយជន ទោះបីជាអ្នកផ្តល់សេវាកម្មនោះបានទទួលព័ត៌មានពីពេលមុនពីការអាចកើតមានឡើងនូវការខូចខាតទាំងនេះក៏ដោយ ឬ (vii) បញ្ហាដទៃទៀតពាក់ព័ន្ធនឹង**សេវាកម្ម**។ ដោយមិនមានការអនុញ្ញាតនូវការបញ្ជូន ឬទិន្នន័យរបស់លោកអ្នក (v) សេចក្តីបញ្ជាក់ ឬការប្រព្រឹត្តរបស់អ្នកណាម្នាក់លើ **សេវាកម្ម** (vi) ការប្រើប្រាស់ អសមត្ថភាពក្នុងការប្រើប្រាស់ ការប្រើប្រាស់ដោយមិនមានការអនុញ្ញាត ដំណើរការ ឬ ភាពមិនដំណើរការនៃគេហទំព័រអ្នកផ្តល់សេវាគណនីតតិយជន ទោះបីជាអ្នកផ្តល់សេវាកម្មនោះបានទទួលព័ត៌មានពីពេលមុនពីភាពអាចកើតមានឡើងនូវការខូចខាតទាំងនេះក៏ដោយ ឬ(vii) បញ្ហាដទៃទៀតពាក់ព័ន្ធនឹង**សេវាកម្ម**។

១៥.៣ ដោយមិនប៉ះពាល់លើភាពទូទៅនៃអ្វីដែលរៀបរាប់ពីមុនមក លោកអ្នកយល់ដឹងថាលោកអ្នកទទួលខុសត្រូវដោយផ្ទាល់ចំពោះការចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត និង/ឬ **គេហទំព័រ** កម្មវិធី និងយល់ព្រមជួសជុលការខូចខាត ការពារ និងធានាឲ្យធនាគាររួចផុតពីរាល់ការប្តឹងផ្តល់ ការទាមទារ សាលក្រម ការខូចខាត ការចំណាយ ការបាត់បង់ ការចាយវាយណាមួយ ឬទាំងអស់នោះទេ (ដោយរួមមានថ្លៃសោហ៊ុយប្រឹក្សាច្បាប់) និងការទទួលខុសត្រូវដទៃទៀតដែលមានកើតឡើងចំពោះ ឬ ទទួលរងដោយធនាគារ ទោះបីជាបណ្តាលដោយសារអ្វី និងដោយមធ្យោបាយណាក៏ដោយ ក្នុងការផ្តល់ សេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័តជូនលោកអ្នក មិនថាកើតឡើងពី ឬពាក់ព័ន្ធនឹងចំណុចខាងក្រោមឬក៏អត់នោះទេ៖

១៥.៣.១ ការខកខានរបស់លោកអ្នកក្នុងការគោរពកាតព្វកិច្ចសុវត្ថិភាពរបស់លោកអ្នក ឲ្យបានខ្ជាប់ខ្ជួនតាមប្រការ ៦ នៃខចែង និងលក្ខខណ្ឌនេះ និង/ឬ សកម្មភាពពេលក្រោយ ឬការលុបចោលរបស់បុគ្គលណាម្នាក់ដែលប្រើប្រាស់ព័ត៌មានសម្គាល់អិនភាគរបស់លោកអ្នកដែលជាលទ្ធផលមួយនៃការខកខានរបស់លោកអ្នកក្នុងការគោរពកាតព្វកិច្ចសុវត្ថិភាពដែលបានរៀបរាប់ខាងលើ

១៥.៣.២ ការរំលោភបំពានលើពាណិជ្ជសញ្ញា ឬសិទ្ធិអ្នកនិពន្ធ ឬកម្មសិទ្ធិបញ្ញាដទៃទៀតរបស់តតិយជន (សូមពិនិត្យមើលប្រការ ១៣ នៃខចែង និងលក្ខខណ្ឌនេះ)

១៥.៣.៣ សកម្មភាពខុសច្បាប់ អសីលធម៌ និង/ឬធ្វេសប្រហែស កំហុសឆ្គង ឬការលុបចោលណាមួយតាមរយៈ **សេវាកម្ម** ដោយរួមមានតែមិនកំណត់ចំពោះឧក្រិដ្ឋកម្មកុំព្យូទ័រ ការបោកបន្លំ ការបោកប្រាស់ ការបរិហារកេរ្តិ៍ ។ល។ (សូមពិនិត្យមើលប្រការ១២ នៃខចែង និងលក្ខខណ្ឌនេះ) និង/ឬការខកខានរបស់លោកអ្នកក្នុងការ

គោរពច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន (សូមពិនិត្យមើលប្រការ១៦ នៃខចែង និងលក្ខខណ្ឌនេះ) និង/ឬ

១៥.៣.៤ ការខកខានរបស់លោកអ្នកក្នុងការធានាថាលោកអ្នកមានមូលនិធិគ្រប់គ្រាន់ក្នុងគណនីរបស់លោកអ្នក។ គូភាគីព្រមព្រៀងថាប្បញ្ញត្តិនេះនឹងមានសុពលភាពអនុវត្តយ៉ាងទូលំទូលាយ និងពេញលេញរហូតដល់កម្រិតដែលបានអនុញ្ញាតដោយច្បាប់។

១៥.៤ បញ្ញត្តិនៃប្រការ១៥នេះនឹងមានសុពលភាពអនុវត្តយ៉ាងទូលំទូលាយ និងពេញលេញរហូតដល់កម្រិតដែលបានអនុញ្ញាតដោយច្បាប់។ សេចក្តីយោងលើពាក្យពេចន៍ "ធនាគារយើងខ្ញុំ" "ធនាគាររបស់យើងខ្ញុំ" ឬ "របស់ធនាគារយើងខ្ញុំ" នៅក្នុងប្រការ ១៥ និងនៅកន្លែងផ្សេងទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ធនាគារ RHB រួមបញ្ចូលនៅពេលដែលអាចអនុវត្តបាន ដៃគូរបស់ធនាគារ RHB និងអ្នកចុះកិច្ចសន្យាជាមួយនឹងធនាគារ RHB ព្រមទាំងអភិបាល និយោជិត បុគ្គលិក ភ្នាក់ងារ និង/ឬអ្នកតំណាងរបស់ធនាគារ RHB។

## ១៦.ការផ្អាក /ការបញ្ចប់សេវាកម្ម

១៦.១ ទោះបីជាមានបញ្ញត្តិដទៃផ្សេងទៀតណាមួយនៅក្នុងខចែង និងលក្ខខណ្ឌនេះក៏ដោយ នៅពេលណាមួយ ដោយមាន និងមិនមានការជូនដំណឹង និងដោយមិនចាំបាច់ផ្តល់ហេតុផលជូនលោកអ្នក ធនាគារយើងខ្ញុំអាចធ្វើការបញ្ឈប់ ផ្អាក ឬបញ្ចប់ភ្លាមៗនូវសេវាធនាគារអ៊ីនធើណែត ឬសេវាធនាគារចល័ត (ឬផ្នែកណាមួយនៃសេវាកម្មនេះ) ឬសិទ្ធិរបស់លោកអ្នកក្នុងការចូលទៅប្រើប្រាស់សេវាធនាគារអ៊ីនធើណែត ឬសេវាធនាគារចល័ត (ឬផ្នែកណាមួយនៃសេវាកម្មនេះ) ដោយមិនមានលក្ខខណ្ឌ ឬបើមិនដូចច្នេះទេ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារយើងខ្ញុំ។ តាមរយៈឆន្ទានុសិទ្ធិដាច់ខាតរបស់ខ្លួន ធនាគារ RHB អាចដាក់លក្ខខណ្ឌមួយចំនួនលើការផ្អាកដំណើរការ ដូចជា រយៈពេលផ្អាកដំណើរការ និង ការដាក់ឲ្យដំណើរការសេវាកម្មឡើងវិញ និង លក្ខខណ្ឌមុននឹងមានការដាក់ឲ្យដំណើរឡើងវិញ។

១៦.២ នៅពេលផ្អាក ឬបញ្ចប់**សេវាកម្ម** ធនាគារយើងខ្ញុំគ្មានកាតព្វកិច្ចក្នុងការអនុវត្តតាមបញ្ជាប្រតិបត្តិការណាមួយរបស់លោកអ្នកនោះទេ ទោះបីជាទទួលបានមុន ឬបន្ទាប់ពីកាលបរិច្ឆេទសុពលភាពនៃការផ្អាក ឬការបញ្ចប់នេះ និងដែលមិនទាន់ត្រូវបានអនុវត្តដោយធនាគារយើងខ្ញុំ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារយើងខ្ញុំ។ ប្រសិនបើមានកិច្ចការ ឬសកម្មភាពដែលមិនទាន់បានបញ្ចប់ដែលធនាគារយើងខ្ញុំតម្រូវឲ្យលោកអ្នកអនុលោមតាម លោកអ្នកត្រូវអនុវត្តរាល់នីតិវិធីដែលបានតម្រូវដោយធនាគារយើងខ្ញុំដើម្បីបំពេញ ឬបញ្ចប់នូវរាល់សកម្មភាពក្រោម ឬអនុលោមតាម**សេវាកម្ម ឬគេហទំព័រ**។ សិទ្ធិ និងអាជ្ញាប័ណ្ណទាំងអស់ដែលបានផ្តល់ជូនលោកអ្នកក្រោមសេវាកម្មនេះ នឹងត្រូវដកហូតយកមកវិញភ្លាមៗ។ ការបញ្ចប់ ឬការផ្អាកដំណើរការសេវាកម្មក្រោមប្រការ ១៦ នៃខចែង និងលក្ខខណ្ឌនេះដោយធនាគារយើងខ្ញុំ នឹងមិនផ្តល់សិទ្ធិដល់លោកអ្នក ហើយតាមរយៈនេះលោកអ្នកបោះបង់សិទ្ធិទាមទារ ឬ ទទួលសំណងណាមួយពីធនាគារយើងខ្ញុំចំពោះការខូចខាត ឬការខាតបង់ណាមួយ និងទាំងអស់ដែលទទួលរង ឬកើតមានឡើងលើលោកអ្នកដែលជាលទ្ធផលដោយផ្ទាល់ ឬដោយប្រយោលនៃសកម្មភាពនៃការបញ្ចប់ ឬការផ្អាកនេះ។

## ១៧. ច្បាប់ និងយុត្តាធិការគ្រប់គ្រង

១៧.១ ខចែង និងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ គូភាគីត្រូវស្ថិតក្រោមយុត្តាធិការផ្តាច់មុខរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា។

១៧.២ ដោយមិនមាន តាមរយៈមធ្យោបាយណាមួយ ធ្វើការកម្រិត ឬប៉ះពាល់លើភាពទូទៅនៃប្រការ ១៧ នៃខចែង និងលក្ខខណ្ឌនេះ លោកអ្នកព្រមព្រៀងថា៖

១៧.២.១ ការចេញ និងការប្រើប្រាស់**សេវាកម្ម** និងខសន្យា និងលក្ខខណ្ឌនេះត្រូវយោងទៅតាមគោលការណ៍ណែនាំ និង/ឬ លិខិតបទដ្ឋានគតិយុត្តជាធរមានតាមពេលវេលាជាក់ស្តែង របស់ធនាគារជាតិនៃកម្ពុជា។

១៧.២.២ រាល់ប្រតិបត្តិការ ឬការប្រើប្រាស់ដោយលោកអ្នកតាម ឬអនុលោមតាម**សេវាកម្ម**នេះ មិនត្រូវរំលោភបំពានច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ឬ(ប្រសិនជាត្រូវអនុវត្ត) ច្បាប់ដែលមាននៅក្នុងប្រទេសមួយ (ច្រើន) ពាក់ព័ន្ធនឹងប្រតិបត្តិការ ឬការប្រើប្រាស់ទាំងអស់ដែលពាក់ព័ន្ធរបស់លោកអ្នក។ វាជាកាតព្វកិច្ចរបស់លោកអ្នកតែឯកឯងក្នុងការអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬប្រទេសផ្សេងទៀតណាមួយ (ច្រើន) ដែលត្រូវអនុវត្ត ដែលយើងខ្ញុំមិនមានកាតព្វកិច្ចក្នុងការជម្រាប ឬជូនដំណឹងលោកអ្នកពីច្បាប់ទាំងនេះទេ។

## ១៨. ការជូនដំណឹង

១៨.១ លើកលែងតែមានការកំណត់ជាក់លាក់ផ្សេងពីនេះនៅក្នុងខចែង និងលក្ខខណ្ឌនេះ ឬមានការជូនដំណឹងដោយធនាគារ RHB ទៅកាន់លោកអ្នកតាមពេលវេលាជាក់ស្តែងនោះទេ ការជូនដំណឹង សេចក្តីណែនាំ ឬទំនាក់ទំនងផ្សេងៗទៀតដែលត្រូវផ្តល់ជូនក្រោមខចែង និងលក្ខខណ្ឌនេះដោយលោកអ្នកទៅធនាគារ RHB ត្រូវធ្វើឡើងតាម រយៈ៖

១៨.១.១ តាមមធ្យោបាយនៃសារសុវត្ថិភាព តាមរយៈសេវាធនាគារអ៊ីនធើណែត ដែលមានប្រសិទ្ធិភាពតែនៅពេលដែលមានការឆ្លើយតបថាបានទទួលដោយធនាគារ RHB តាមរយៈសារសុវត្ថិភាពទៅកាន់លោកអ្នក តាមរយៈសេវាធនាគារអ៊ីនធើណែត

១៨.១.២ ជាលាយលក្ខណ៍អក្សរដែលបានចុះហត្ថលេខាដោយលោកអ្នក និងបានផ្ញើតាមប្រៃណីយ៍ដែលត្រូវបានចុះបញ្ជី ដែលមានសុពលភាពនៅពេលដែលត្រូវបានទទួលដោយធនាគារ RHB តាមរយៈអាសយដ្ឋានដូចខាងក្រោម៖

RHB Indochina Bank Limited (០០០០១៨១២)
**នាយកដ្ឋានសេវាធនាគារឌីជីថល**
**# ២៦៣ ផ្លូវអង្គឌួង (ផ្លូវលេខ ១១០)**
**ភ្នំពេញ កម្ពុជា**

១៨.២ បន្ថែមពីលើមធ្យោបាយជាទូទៅ ធនាគារ RHB អាចផ្តល់ការជូនដំណឹងដល់លោកអ្នកតាមរយៈមធ្យោបាយដូចខាងក្រោមតាមឆន្ទានុសិទ្ធផ្តាច់មុខរបស់របស់ធនាគារ RHB៖

១៨.២.១ ដោយសារសុវត្ថិភាពតាមរយៈសេវាធនាគារអ៊ីនធើណែត ដែលមានសុពលភាពក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីការផ្ញើ

១៨.២.២ តាមរយៈសារអេឡិចត្រូនិចទៅកាន់អាសយដ្ឋានសារអេឡិចត្រូនិចអនុលោមតាមកំណត់ត្រារបស់ធនាគារ RHB ដែលមានសុពលភាពក្នុងរយៈពេល២៤ម៉ោងបន្ទាប់ពីការផ្ញើរ

១៨.២.៣ តាមរយៈការបង្ហោះការជូនដំណឹង ឬការទំនាក់ទំនងនៅលើ**គេហទំព័រ** ដែល (ប្រសិនជាមិនត្រូវបានកំណត់នៅក្នុងការជូនដំណឹងឬការទំនាក់ទំនងនេះទេនោះ) ត្រូវមានសុពលនៅកាលបរិច្ឆេទនៃការបង្ហោះ

១៨.២.៤ តាមរយៈមធ្យោបាយដទៃទៀតនៃការជូនដំណឹងតាមឆន្ទានុសិទ្ធិរបស់ធនាគារRHB តាមពេលវេលាជាក់ស្តែង។

១៨.៣ លើកលែងតែមានការកំណត់ជាក់លាក់ក្រោមខចែង និងលក្ខខណ្ឌនេះចំពោះពេលវេលាជាក់លាក់សម្រាប់ជូនដំណឹង ការជូនដំណឹងណាមួយដែលបានផ្តល់ជូន ឬតម្រូវឲ្យផ្តល់ជូនដោយធនាគារ RHB ក្រោមខចែង និងលក្ខខណ្ឌនេះ អាចត្រូវបានផ្តល់ជូនក្នុងឥរិយាបថដែលធនាគារ RHB គិតថាស័ក្តិសម និងដោយមានសុពលភាពភ្លាមៗ ឬក្នុងអំឡុងពេលណាមួយតាមឆន្ទានុសិទ្ធរបស់ធនាគារ RHB។

## ១៩. ការសាកសួរ និងការដោះស្រាយវិវាទ

១៩.១ ប្រសិនជាលោកអ្នកមានសំណួរដែលត្រូវការជំនួយបន្ថែម ពាក់ព័ន្ធនឹងសេវាធនាគារអ៊ីនធើណែត និងសេវាធនាគារចល័ត លោកអ្នកអាចហៅទូរស័ព្ទមកកាន់លេខ (៨៥៥) ១៦ ៩៨៨ ២៨៨ ឬផ្ញើអ៊ីម៉ែលមកកាន់ kh.customerservice@rhbgroup.com ។ នៅក្នុងករណីដែលលោកអ្នកមានបណ្តឹង ឬវិវាទ សូមសរសេរជាលាយលក្ខណ៍អក្សរមកកាន់អាសយដ្ឋានខាងក្រោម ឬទំនាក់ទំនងមកយើងខ្ញុំតាមរយៈលេខទូរស័ព្ទ (៨៥៥) ១៦ ៩៨៨ ២៨៨និងបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងរបស់លោកអ្នក។

**ផ្នែកបម្រើសេវាអតិថិជន**
RHB Indochina Bank Limited
**# ២៦៣ ផ្លូវអង្គឌួង (ផ្លូវលេខ១១០)**
**ភ្នំពេញ កម្ពុជា**
**ទូរសារ៖ (៨៥៥) ២៣ ៩៩១ ៨២២**

១៩.២ លោកអ្នកអាចត្រូវបានតម្រូវឲ្យបង្ហាញព័ត៌មានដែលពាក់ព័ន្ធទាំងអស់ពាក់ព័ន្ធនឹងការសាកសួរ ឬបណ្តឹង ឬវិវាទរបស់លោកអ្នក ប៉ុន្តែមិនកំណត់ចំពោះតែ ឈ្មោះ លេខគណនីពាក់ព័ន្ធ ការរៀបរាប់បញ្ជាក់ពីសំណួរ ឬបណ្តឹងរបស់លោកអ្នក ចំនួនទឹកប្រាក់ដែលពាក់ព័ន្ធនឹងសំណួរ ឬបណ្តឹង ដែលអាចពាក់ព័ន្ធ។ នៅពេលដែលការទំនាក់ទំនងណាមួយពាក់ព័ន្ធនឹងព័ត៌មានសំងាត់របស់លោកអ្នកទាក់ទងនឹងគណនី ឬប្រតិបត្តិការរបស់លោកអ្នកដែលបានធ្វើឡើងពាក់ព័ន្ធនឹងសំណួរ ឬបណ្តឹងរបស់លោកអ្នក ធនាគារយើងខ្ញុំលើកទឹកចិត្តឲ្យធ្វើការទំនាក់ទំនងតាមរយៈសារសុវត្ថិភាព។ នៅក្នុងករណីដែលលោកអ្នកបន្តក្នុងការធ្វើការទំនាក់ទំនងអំពីព័ត៌មាននេះតាមរយៈសារដែលមិនមានសុវត្ថិភាព លោកអ្នកព្រមព្រៀងថា លោកអ្នកទទួលខុសត្រូវចំពោះហានិភ័យពាក់ព័ន្ធនឹងមធ្យោបាយទំនាក់ទំនង

នេះ ហើយមិនត្រូវ នៅពេលណាមួយក៏ដោយ ទាមទារឲ្យធនាគារ RHB ទទួលខុសត្រូវ ឬទទួលរ៉ាប់រងចំពោះសុវត្ថិភាពចំពោះព័ត៌មាននេះ ឬការបាត់បង់ណាមួយដែលទទួលរងពាក់ព័ន្ធនឹងអ្វីដែលបានរៀបរាប់នោះទេ។

១៩.៣ បណ្ដឹង និងសំណួររបស់លោកអ្នកនឹងត្រូវបានស៊ើបអង្កេត និងទទួលបានការយកចិត្តទុកដាក់។ សំណួរ ឬ បណ្ដឹងផ្ទាល់មាត់ នឹងត្រូវបានដោះស្រាយជូនក្នុងអំឡុងពេល ២ (ពីរ) ថ្ងៃធ្វើការបន្ទាប់ពីការទទួលសំណួរ ឬបណ្ដឹងនេះ។ សំណួរ ឬ បណ្ដឹងជាលាយលក្ខណ៍អក្សរ នឹងត្រូវបានដោះស្រាយជូន មិនឲ្យលើសពី ៣០ (សាមសិប) ថ្ងៃប្រតិទិនបន្ទាប់ពីទទួលបានសំណួរ ឬ បណ្ដឹង។

១៩.៤ នៅក្នុងករណីដែលទាមទារឲ្យមានពេលវេលាបន្ថែមទៀតក្នុងការស៊ើបអង្កេត អំឡុងពេលដែលបានកំណត់ក្នុងប្រការ ១៩.៣ ខាងលើនឹងត្រូវបានពន្យាដោយបន្ថែមនូវអំឡុងពេលដែលសមហេតុផលដែលចាំបាច់។ អតិថិជននឹងទទួលបានដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈសារសុវត្ថិភាពពីហេតុផលនៃការពន្យាពេល និងតម្រូវការពេលវេលាបន្ថែមដើម្បីដោះស្រាយបណ្ដឹង។

១៩.៥ នៅពេលដែលលោកអ្នកមិនពេញចិត្តនឹងលទ្ធផលនៃការស៊ើបអង្កេត ឬបណ្ដឹងរបស់លោកអ្នក លោកអ្នកអាចធ្វើការតវ៉ាចំពោះលទ្ធផលនេះដោយបញ្ជូនបណ្ដឹងនេះទៅកាន់ ធនាគារជាតិនៃកម្ពុជា។ (សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យមើលគោលនយោបាយ និងនីតិវិធីដោះស្រាយបណ្ដឹងអតិថិជនរបស់ធនាគារ អ អេច ប៊ី)

## ២០. គោលការណ៍ភាពឯកជន

២០.១ តាមរយៈការចុះឈ្មោះដោយជោគជ័យជាអ្នកប្រើប្រាស់សេវាធនាគារអ៊ីនធើណែត ឬសេវាធនាគារចល័តរបស់ធនាគារ RHB និងការចូលទៅប្រើប្រាស់**សេវាកម្ម** លោកអ្នកទទួលស្គាល់ថាលោកអ្នកបានអាននូវ សេចក្ដីជូនដំណឹងពីភាពឯកជនរបស់ធនាគារ RHB និងបានយល់ព្រមឲ្យធនាគារRHB ប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកក្នុងតរិយាបថដែលបានបញ្ជាក់ ដោយរួមមានការបង្ហាញជាចាំបាច់ និងការផ្ទេរទៅបរទេសដល់ភាគីតតិយជនដែលពាក់ព័ន្ធតាមការតម្រូវ។

២០.២ ធនាគារ RHB ផ្ដល់តម្លៃយកចិត្តដាក់ខ្ពស់ចំពោះការជឿទុកចិត្តរបស់លោកអ្នកលើធនាគារយើងខ្ញុំ ហើយគោរពភាពចាំបាច់ក្នុងការរក្សានូវសុវត្ថិភាព និងការសំងាត់នៃព័ត៌មានដែលលោកអ្នកផ្ដល់ជូនដល់ធនាគារយើងខ្ញុំក្នុងនាមជាអតិថិជនរបស់ RHB ដែលបានចុះឈ្មោះប្រើប្រាស់**សេវាកម្ម**។ ដូចនេះធនាគារយើងខ្ញុំប្ដេជ្ញាចិត្តការពារភាពឯកជន របស់អតិថិជនដូចដែលបានចែងក្នុងគោលការណ៍ភាពឯកជនរបស់ធនាគារយើងខ្ញុំ។

## ២១. ការសំងាត់

លោកអ្នកយល់ព្រម និងអនុញ្ញាតឲ្យធនាគារ RHB អភិបាល មន្ត្រី និយោជិត ភ្នាក់ងារ និង/ឬអ្នកតំណាងរបស់ធនាគារ RHB និងបុគ្គលផ្សេងដទៃទៀតដែលយោងទៅតាមការទទួលខុសត្រូវ ឬមុខតំណែងរបស់ពួកគេ មានសិទ្ធិទទួលព័ត៌មានឬឯកសាររបស់លោកអ្នកពាក់ព័ន្ធនឹងកិច្ចការ ឬគណនីរបស់លោកអ្នក ដើម្បីបង្ហាញ/ចែករំលែកព័ត៌មាន ឬឯកសារទៅក្រុមហ៊ុនដទៃក្នុងសម្ព័ន្ធធនាគារ RHB (សម្រាប់គោលបំណងនៃប្រការ២១នេះ ដែលត្រូវរួមបញ្ចូលក្រុមហ៊ុនមេរបស់ធនាគារ RHB បុត្រសម្ព័ន្ធរបស់ធនាគារ RHB ក្រុមហ៊ុនពាក់ព័ន្ធ និង/ឬក្រុមហ៊ុន/សាខាណាមួយដែលជាលទ្ធផលនៃការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការរំលាយបញ្ចូលគ្នា ការលក់ ឬលទ្ធកម្ម) មិនថានៅក្នុងឬក្រៅប្រទេសកម្ពុជានោះទេ សម្រាប់

គោលបំណងក្នុងការផ្តល់ជូនលោកអ្នកនូវ**សេវាកម្ម** រួមមាន ដោយមិនកំណត់ត្រឹមតែ ការផ្តល់យោបល់ដល់ខ្ញុំ/យើងខ្ញុំពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្ញុំ/យើងខ្ញុំ និង/ឬ ការលក់ដល់អតិថិជនដែលមានស្រាប់ ការធ្វើទីផ្សារ និងផ្សព្វផ្សាយផលិតផល និងសេវាកម្មរបស់សម្ព័ន្ធធនាគារ RHB។

## ២២. ការផ្តាច់ចេញពីគ្នានៃខសន្យា និងលក្ខខណ្ឌ

ប្រសិនជាបញ្ញត្តិណាមួយ ឬផ្នែកនៃបញ្ញត្តិណាមួយនៃខចែង និងលក្ខខណ្ឌនេះអសុពលភាព ឬក្លាយទៅជាអសុពលភាព មិនស្របច្បាប់ ឬមិនអាចអនុវត្តបាន បញ្ញត្តិនោះនឹងត្រូវបានកែសម្រួលក្នុងកម្រិតមួយដែលធ្វើឲ្យវាមានសុពលភាពស្របច្បាប់ និងអាចអនុវត្តបាន។ ប្រសិនជាការកែសម្រួលនេះមិនអាចធ្វើទៅបាន បញ្ញត្តិដែលពាក់ព័ន្ធ ឬផ្នែកនៃប្បញ្ញត្តិនេះត្រូវបានចាត់ទុកថាត្រូវបានលុបចោល។ ការកែសម្រួល ឬការលុបចោលនូវបញ្ញត្តិ ឬផ្នែកនៃបញ្ញត្តិតាមប្រការនេះនឹងមិនត្រូវប៉ះពាល់ដល់សុពលភាព និងអនុភាពអនុវត្តរបស់ផ្នែកដែលសេសសល់នៃកិច្ចព្រមព្រៀងនេះនោះទេ។

## ២៣. បញ្ញត្តិទូទៅ

២៣.១ ខសន្យា និងលក្ខខណ្ឌនេះត្រូវបានអានជាមួយគ្នានឹងខចែងស្តង់ដារ។ នៅក្នុងករណីដែលមានអសង្គតិភាព ឬមានភាពមិនស្របគ្នារវាងខចែង និងលក្ខខណ្ឌនេះ និងខចែងស្តង់ដារ ខចែង និងលក្ខខណ្ឌនេះត្រូវមានអធិកភាពចំពោះតែបញ្ញត្តិដែលអសង្គតភាព ឬមិនស្របគ្នានេះតែប៉ុណ្ណោះ។ continue

២៣.២ ធនាគារ RHB រក្សាសិទ្ធិគ្រប់ពេលវេលាក្នុងការផ្លាស់ប្តូរ កែសម្រួល លុបចោល ឬបន្ថែមទៅលើខចែង និងលក្ខខណ្ឌនេះ ដោយធ្វើការជូនដំណឹងជូនលោកអ្នកជាមុនពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។ យ៉ាងណាមិញ នៅក្នុងករណីបន្ទាន់ ឬក្នុងគោលបំណងការពារសុវត្ថិភាព នៃសេវាធនាគារអ៊ីនធើណែត/សេវាធនាគារចល័ត ឬនៅក្នុង កាលៈទេសៈដទៃទៀត ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារយើងខ្ញុំ នៅពេលដែលធនាគារ RHB គិតថាមានភាពចាំបាច់ក្នុងការផ្លាស់ប្តូរ កែសម្រួល លុបចោល ឬបន្ថែមទៅលើខចែង និងលក្ខខណ្ឌនេះដោយមិនចាំបាច់ជូនដំណឹងដល់លោកអ្នក ធនាគារ RHB នឹងជម្រាបលោកអ្នកនូវការផ្លាស់ប្តូរទាំងនេះភ្លាមៗដូចដែលអាចធ្វើទៅបាននៅពេលក្រោយមក និង/ឬពីហេតុផលនៃការផ្លាស់ប្តូរទាំងនេះ។ លោកអ្នកទទួលយកថា ដើម្បីទទួលបានព័ត៌មានពីការផ្លាស់ប្តូរ ការកែសម្រួល ការលុបចោល ឬការបន្ថែមទៅលើខចែង និងលក្ខខណ្ឌនេះ លោកអ្នកយល់ព្រមចូលទៅប្រើប្រាស់ និងអានដោយប្រុងប្រយ័ត្ននូវខចែង និងលក្ខខណ្ឌនេះតាមវេលាជាក់ស្តែង និងជាទៀង ទាត់។ លោកអ្នកព្រមព្រៀង និងទទួលយកបន្ថែមទៀតថាការបន្តចូលទៅប្រើប្រាស់របស់លោកអ្នកលើខចែង និងលក្ខខណ្ឌនេះ (ដូចដែលបានផ្លាស់ប្តូរ និងកែសម្រួលតាមពេលវេលាជាក់ស្តែង) គឺស្មើនឹងការទទួលយកនូវការផ្លាស់ប្តូរ ការលុបចោល ការកែសម្រួល ឬបន្ថែមទៅលើខចែង និងលក្ខខណ្ឌនេះ។

២៣.៣ ចំណងជើងដែលបានប្រើប្រាស់នៅក្នុងខចែង និងលក្ខខណ្ឌនេះ គឺសម្រាប់សេចក្តីយោង និងភាពងាយស្រួលប៉ុណ្ណោះ និងមិនត្រូវយកមកពិចារណាក្នុងការបកស្រាយខចែង និងលក្ខខណ្ឌនេះនោះទេ។

២៣.៤ កំណត់ត្រារបស់ធនាគារ RHB នៃការទំនាក់ទំនងទាំងអស់ និងណាមួយដោយលោកអ្នកក្នុងអំឡុងពេល ឬអនុលោមតាមការចូលទៅប្រើសេវាធនាគារអ៊ីនធើណែត/ សេវាធនាគារចល័តក្នុងទម្រង់ណាមួយ ឬមធ្យោបាយណាមួយក៏ដោយ (រួមទាំងប្រព័ន្ធផ្សព្វផ្សាយដែលរក្សាទុកព័ត៌មានជាអេឡិចត្រូនិច) គឺជាភ័ស្តុតាងដែលមិនអាច

ប្រកែកបាន។ ការទំនាក់ទំនងទាំងអស់ និងណាមួយដែលបានបញ្ជូនតាមរយៈសេវាធនាគារអ៊ីនធើណេត/ សេវាធនាគារចល័តស្របទៅតាមខចែងនិងលក្ខខណ្ឌនេះ ត្រូវបានចាត់ទុកថាមានសុពលភាព ត្រឹមត្រូវ ពិតប្រាកដ និងត្រូវមានសុពលភាពដូចគ្នាទៅនឹងឯកសារដែលបានសរសេរជាលាយលក្ខណ៍អក្សរ និង/ឬបានចុះហត្ថលេខា។

២៣.៥ ខចែង និងលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងជាភាសាខ្មែរ និងភាសាអង់គ្លេស។ នៅក្នុងករណីដែលមានអសង្គតភាពរវាងឯកសារទាំងពីរនេះ ភាសាអង់គ្លេសនឹងមានអធិកភាព។